

# ប្រវត្តិខេត្តព្រះសីហនុ

ឯកសារចងក្រងប្រវត្តិ និងការវិវត្ត
នៃការគ្រប់គ្រង ដឹកនាំរបស់ខេត្តព្រះសីហនុទៅតាមសម័យកាល




បោះពុម្ពផ្សាយលើកទី១ ឆ្នាំ២០១៦

# អារម្ភកថា



រដ្ឋបាលខេត្តព្រះសីហនុ បានរៀបចំ ចងក្រងប្រវត្តិខេត្ត និងការវិវត្តនៃការគ្រប់គ្រង ដឹកនាំ របស់ខេត្តព្រះសីហនុ ដែលជាឯកសារប្រវត្តិសាស្ត្រមួយរបស់ខេត្ត សម្រាប់មន្ត្រីរាជការ សិស្ស និស្សិត ប្រជាពលរដ្ឋនៅក្នុង ខេត្តព្រះសីហនុ ក៏ដូចជាអ្នកអានទូទៅ បានសិក្សាឈ្វេងយល់នូវការវិវត្ត ប្រែប្រួល ក្នុងការដឹកនាំពីដំណាក់កាលមួយទៅដំណាក់កាលមួយ។

អត្ថបទស្រាវជ្រាវនេះ ក៏ជាចំណេះដឹងមួយ សម្រាប់អ្នកអានទូទៅ បានស្វែងយល់ពីការកកើតខេត្តព្រះសីហនុ ការផ្លាស់ប្តូរឈ្មោះរបស់ខេត្ត និងការប្រែប្រួលភូមិសាស្ត្រនៃការគ្រប់គ្រង ដឹកនាំតាំងពីការចាប់ផ្តើមរហូតមកដល់បច្ចុប្បន្ន។ ការរៀបចំ ចងក្រងប្រវត្តិខេត្តព្រះសីហនុ ក៏ដូចជា ការលើកទឹកចិត្តដល់សិស្ស និស្សិត មន្ត្រីរាជការ និងអ្នកអានទូទៅ ខិតខំស្រាវជ្រាវ នូវប្រវត្តិដែលបានកើតមានឡើង ក្នុងទឹកដីខេត្តព្រះសីហនុ ចាប់ផ្តើមកកើត និងអភិវឌ្ឍន៍ តាំងពីជំនាន់ដើម រហូតមកដល់បច្ចុប្បន្ន ដែលប្រជាពលរដ្ឋទូទៅ មិនធ្លាប់បានដឹង។

ការរៀបចំចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រង ដឹកនាំរបស់ខេត្តព្រះសីហនុនេះ មានគោលបំណងដូចខាងក្រោម៖

-លើកស្ទួយវិស័យកំពង់ផែសេដ្ឋកិច្ច(ពាណិជ្ជកម្ម) អន្តរជាតិ មជ្ឈមណ្ឌលទេសចរណ៍(ធម្មជាតិ) និងតំបន់ឧស្សាហកម្ម សេដ្ឋកិច្ចពិសេស ដោយខេត្តព្រះសីហនុ គឺជាខេត្តមួយ ដែលរាជរដ្ឋាភិបាលកម្ពុជា បានកំណត់ជាប៉ូលសេដ្ឋកិច្ចមួយ ក្នុងចំណោមប៉ូលសេដ្ឋកិច្ចទាំង៣ និង ជាតំបន់សេដ្ឋកិច្ចពិសេសពហុ-បំណង នៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងនោះផងដែរ អ្នកទេសចរណ៍ជាតិ និងអន្តរជាតិ ដែលមកកំសាន្តនៅខេត្តព្រះសីហនុ គឺពិតជាចង់ឈ្វេងយល់ឱ្យកាន់តែច្បាស់អំពី ប្រវត្តិនៃការកកើតខេត្ត ដ៏ស្រស់បំព្រងមួយនេះជាក់ជាពុំខាន។

-មន្ត្រីរាជការ សិស្ស និស្សិត ប្រជាពលរដ្ឋរស់នៅ ក្នុងខេត្តព្រះសីហនុ ត្រូវដឹងពីប្រវត្តិ ទឹកដីដែលយើងកំពុងរស់នៅ និងជាមូលដ្ឋាន សម្រាប់អ្នកសិក្សាស្រាវជ្រាវ។

-រកហេតុផល និងមូលដ្ឋាន ឱ្យបានច្បាស់លាស់ នូវការដាក់ឈ្មោះ កំពង់សោម និងព្រះសីហនុ ជៀសវាង ភាពមិនច្បាស់លាស់ សម្រាប់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយ។

-ក្រុង-ស្រុក-ឃុំ-សង្កាត់ បានយល់ ពីតម្លៃ នៃការចងក្រងប្រវត្តិ ក្នុងមូលដ្ឋានរបស់ខ្លួន។

ក្នុងនាមអភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ និងជាប្រធានក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ ខ្ញុំសូមថ្លែងអំណរគុណដល់ ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ ក្រុមលេខានៃក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ និងអ្នកពាក់ព័ន្ធនានា ដែលបានចូលរួមយ៉ាងសកម្ម នៅក្នុងដំណើរការ នៃការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិខេត្តនេះឡើងរហូតសម្រេចជាស្ថាពរ ។

ចំពោះការរៀបចំចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រងដឹកនាំ ខេត្តព្រះសីហនុនេះ មិនអាចបំពេញបាននូវតម្រូវការ របស់អ្នកអានយកទៅសិក្សាស្រាវជ្រាវ ឱ្យបានទូលំទូលាយ គ្រប់ជ្រុងជ្រោយនោះទេ ដោយសារការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំ មានដែនកំណត់ ។ យើងខ្ញុំនឹងរង់ចាំស្វាគមន៍ ការបំពេញបន្ថែម នូវគំនិតល្អៗ និងការរិះគន់ក្នុងន័យស្ថាបនា ពីអស់លោកអ្នក ។

ធ្វើនៅខេត្តព្រះសីហនុ ថ្ងៃទី.......... ខែ.......... ឆ្នាំ២០១៦

**អភិបាលខេត្ត**

យន្ត. មីន

**រក្សាសិទ្ធិដោយ រដ្ឋបាលខេត្តព្រះសីហនុ**

សម្រាប់ការចូលរួមផ្តល់មតិយោបល់ និងឯកសារពាក់ព័ន្ធផ្សេងៗ សូមទំនាក់ទំនងមកក្រុមការងារតាមរយៈអាស័យដ្ឋានខាងក្រោម៖


គេហទំព័រ៖ www.sihanoukville.gov.kh

ហ្វេសបុក៖ https://www.facebook.com/preahsihanoukprovincialadministration

អ៊ីម៉ែល៖ kheang.phearom@gmail.com

ទូរស័ព្ទ៖ ០១៦៣២១០១០

# សេចក្តីផ្តើម

ផ្អែកតាមការវិវត្តរបស់ប្រទេសជាតិ ពីសម័យកាលមួយទៅសម័យកាលមួយទៀត បានធ្វើឱ្យមានការប្រែប្រួល ស្ថានភាពភូមិសាស្ត្រ រដ្ឋបាល ប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច និងការគ្រប់គ្រងនៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅទូទាំងប្រទេស ។ ក្នុងនោះផងដែរ ក្រសួងមហាផ្ទៃ មានគម្រោងចងក្រងនូវប្រវត្តិរបស់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅទូទាំងប្រទេស ដើម្បីរក្សាទុកជាឯកសារសម្រាប់បម្រើឱ្យការសិក្សាអំពីប្រវត្តិនៃការកកើត និងការវិវត្តនៃការគ្រប់គ្រង ដឹកនាំ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងសម្រាប់បម្រើឱ្យការងារផ្សេងៗទៀត។

យោងសេចក្តីជូនដំណឹងលេខ១៥៦៩ សជណ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ ស្តីពីការសិក្សា ស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។ រដ្ឋបាលខេត្តព្រះសីហនុ បានរៀបចំ សិក្សា ស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំខេត្តព្រះសីហនុ ក្រោមការដឹកនាំ សម្របសម្រួល របស់ ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្ត ដោយបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ ដែលមានក្រុមលេខា នៃក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ ជាសេនាធិការ និងមានការចូលរួមផ្តល់យោបល់ ពីអ្នកពាក់ព័ន្ធនានាផងដែរ ។

ការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំខេត្តព្រះសីហនុ បានចែកចេញជាបីដំណាក់កាលដូចខាងក្រោម៖

- **ដំណាក់កាលទី១៖**ស្រាវជ្រាវឯកសារ និងប្រមូលទិន្នន័យពាក់ព័ន្ធនានាឱ្យបានជាអតិបរមា ដោយស្រាវជ្រាវ ឯកសារពាក់ព័ន្ធ នានា និងចុះសាកសួរសាក្សីរស់ ជាចាស់ព្រឹទ្ធាចារ្យ អតីតមន្ត្រីរាជការ អតីតថ្នាក់ដឹកនាំខេត្ត និងអ្នកដែលបានដឹង ពីស្ថានភាពពិត ទាក់ទងទៅនឹងការករកើតខេត្តព្រះសីហនុ ការផ្លាស់ប្តូរឈ្មោះខេត្ត ទៅតាមសម័យកាល ការគ្រប់គ្រងរដ្ឋបាល និងការកែសម្រួលព្រំប្រទល់ដែនដី ប្រវត្តិថ្នាក់ដឹកនាំខេត្ត និងសមិទ្ធផលដែលសម្រេចបាន ពីសម័យកាលមួយ ទៅសម័យកាលមួយ ។

- **ដំណាក់កាលទី២៖** រៀបចំសេចក្ដីព្រាងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រង ដឹកនាំរបស់ខេត្តព្រះសីហនុ ដើម្បីដាក់ប្រជុំពិភាក្សា និងផ្ដល់យោបល់ ពីក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការ វិវត្តិនៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ ។
- **ដំណាក់កាលទី៣៖** រៀបចំបច្ចុប្បន្នភាព សេចក្ដីព្រាងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រង ដឹកនាំរបស់ខេត្តព្រះសីហនុ ដើម្បីដាក់ប្រជុំពិភាក្សា និងផ្ដល់យោបល់ សម្រេច ពីក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំខេត្តព្រះសីហនុ ។

នៅក្នុងដំណើរការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ត្រូវជានាឱ្យមានការចូលរួមផ្ដល់យោបល់ ឱ្យបានគ្រប់ជ្រុងជ្រោយ ពីអ្នកពាក់ព័ន្ធ ព្រមទាំងប្រមូលនូវឯកសារដែលជាភស្តុតាង ឬការអះអាងដែលអាចបង្ហាញអំពីស្ថានភាពពិតប្រាកដ ដែលបានកើតមានឡើងតាមសម័យកាលនីមួយៗ ទៅតាមមាតិកាដូចខាងក្រោម៖

I. **ទិដ្ឋភាពទូទៅ**
II. **ប្រវត្តិនៃការកកើតខេត្ត**
III. **ការកែសម្រួលព្រំប្រទល់រដ្ឋបាល ឬការប្ដូរឈ្មោះខេត្ត**
IV. **ចំនួន និងឈ្មោះក្រុងស្រុក ឃុំសង្កាត់ចំណុះខេត្ត**
V. **ការគ្រប់គ្រងដឹកនាំខេត្ត**

# មាតិកា

**ចំណងជើង** **ទំព័រ**


អារម្ភកថា ............................................................ i
សេចក្តីផ្តើម ............................................................ iV
ផែនទីរដ្ឋបាលខេត្ត ............................................................ Vi
មាតិកា ............................................................ Vii
រូបភាព ............................................................ X

I. **ទិដ្ឋភាពទូទៅ** ............................................................ **១**
II. **ប្រវត្តិនៃការកកើតខេត្ត** ............................................................ **២**
១ .លក្ខណៈទូទៅរបស់ទីក្រុងកំពង់សោម នៅឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៨៦ ............................................................ ៣
២ .ឈូងសមុទ្រក្រុងកំពង់សោម ............................................................ ៣
៣ .គំនិតផ្តួចផ្តើម នៃការបង្កើតកំពង់ផែសមុទ្រ ............................................................ ៤
៤ .ការជ្រើសរើសទីតាំង កំពង់ផែសមុទ្រ ............................................................ ៦
៥ .មូលហេតុដែលដាក់ឈ្មោះ តំបន់នេះថា កំពង់សោម ............................................................ ១១

III. **ការកែសម្រួលព្រំប្រទល់ និងការប្តូរឈ្មោះខេត្ត** ............................................................ **១២**
១. មណ្ឌលរ៉េស៊ីដង់កំពត ត្រូវបង្កើតឱ្យទៅជាខេត្តតែមួយ ............................................................ ១៤
២. ការកែសម្រួល ស្រុកធំៗទាំងបី ដែលចំណុះខេត្តកំពត ទៅជាប្រាំពីរស្រុក ............................................................ ១៥
៣. ការបង្កើតទីក្រុងកំពង់សោម ............................................................ ១៦
៤. ការប្តូរឈ្មោះ ក្រុងកំពង់សោម ទៅជាក្រុងព្រះសីហនុ ............................................................ ១៧
៥. ក្រុងព្រះសីហនុ ត្រូវបានតំឡើងឋានៈជារាជធានីទី២ ............................................................ ១៧
៦. ក្រុងព្រះសីហនុ ត្រូវបានប្តូរឈ្មោះមក ក្រុងកំពង់សោម វិញ ............................................................ ១៧
៧. ក្រុងកំពង់សោម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ............................................................ ១៨
៨. ដំណាក់កាល ស្តារ និងអភិវឌ្ឍ ក្រុងកំពង់សោម ............................................................ ១៨
៩. បង្កើតខ័ណ្ឌចំណុះ ក្រុងកំពង់សោម ............................................................ ១៨
១០. ក្រុងកំពង់សោម ត្រូវបានប្តូរឈ្មោះ ទៅជាក្រុងព្រះសីហនុ វិញ ............................................................ ១៨

១១. ក្រុងព្រះសីហនុ ត្រូវប្តូរមកជា ខេត្តព្រះសីហនុ ....................១៨
១២. កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ....................១៩
១៣. បង្កើតឃុំកែវផុស ចំណុះឱ្យ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ .................... ២០
១៤. បង្កើតឃុំតានៃ ចំណុះឱ្យ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ .................... ២០
១៥. បង្កើតសង្កាត់កោះរ៉ុងសន្លឹម ចំណុះឱ្យ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ .................... ២១

IV. **ចំនួន និងឈ្មោះក្រុង ស្រុក ឃុំ សង្កាត់ ចំណុះខេត្ត**....................**២១**
១. ក្រុងព្រះសីហនុ មាន ០៦ សង្កាត់ .................... ២១
២. ស្រុកព្រៃនប់ មាន ១៥ ឃុំ .................... ២១
៣. ស្រុកស្ទឹងហាវ មាន ៤ ឃុំ....................២២
៤. ស្រុកកំពង់សីលា មាន ៤ ឃុំ ....................២២

V. **សមិទ្ធិផលសំខាន់ៗរបស់ក្រុងព្រះសីហនុ**....................**២២**
១. ផ្លូវជាតិលេខ៤....................២៣
២. កំពង់ផែ ....................២៣
៣. ផ្លូវដែក .................... ២៦
៤. ផ្លូវអាកាស ....................២៧
៥. សណ្ឋាគារឯករាជ្យ .................... ២៨
៦. ព្រះរាជដំណាក់ .................... ២៨
៧. ស្ថានីយអយស្ម័យយានក្រុងព្រះសីហនុ .................... ២៩
៨. រោងចក្រចម្រាញ់ប្រេងកាត....................៣២
៩. រោងចក្រដំឡើងត្រាក់ទ័រ ....................៣២
១០. រោងចក្រស្រាបៀរអង្គរ ....................៣៣
១១. រោងចក្រផលិតទឹកកក.................... ៣៤
១២. ធនាគារជាតិ.................... ៣៤
១៣. ព្រះវិហារកាតូលិក St Michael Church .................... ៣៤
១៤. វត្តដោតញ្ញាណ (វត្តលើ) .................... ៣៥
១៥ .វត្តឥន្ទញ្ញាណ (វត្តក្រោម).................... ៣៥

១៦.វិមានឯករាជ្យ ........ ៣៦
១៧. វេទិកា៧មករា ........ ៣៦
១៨. រូបសំណាក តោពីរ ........ ៣៧
១៩. ស្ពានតេជោមរកត ឬ ស្ពានកោះពស់ឆ្លងសមុទ្រ ........ ៣៧

VI. **ការគ្រប់គ្រងដឹកនាំខេត្ត** ........ **៣៨**
ពីឆ្នាំ១៩៥៧ ដល់ឆ្នាំ១៩៧០ ........ ៣៨
ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ ........ ៣៨
ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ........ ៣៨
ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ២០០៣ ........ ៣៨
ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៨ ........ ៣៩
ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤ ........ ៣៩
ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥ ........ ៤០
ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ដល់ឆ្នាំ២០១៦ ........ ៤១

# រូបភាព

**ចំណងជើង** **ទំព័រ**

រូបភាពលេខ០១៖ ព្រែកកំពង់សោម ដែលហូរចាក់ទៅក្នុងឆកកំពង់សោមដែរនោះ ស្ថិតនៅក្បែរស្រែអំបិល ដោយទទួលទឹកខាងស្តាំដៃពីស្ទឹងកំបុត និងស្ទឹងសំរោង ........ ២
រូបភាពលេខ០២៖ ឆកកំពង់សោម និងកោះរុង កោះរុងសន្លឹម ........ ៤
រូបភាពលេខ០៣៖ ក្រុមការងារវិស្វករចុះសិក្សាស្រាវជ្រាវ ទីតាំងសាងសង់កំពង់ផែ ........ ៥
រូបភាពលេខ០៤៖ ទីតាំងឆ្នេរនៅខាងមុខកោះពស់ ........ ៧
រូបភាពលេខ០៥៖ ទីតាំងឆ្នេរនៅទល់មុខកោះពស់ (ឆ្នេរលំហែកាយ) ........ ៨
រូបភាពលេខ០៦៖ គន្លងទឹកនៅចន្លោះកោះពស់ និងឆ្នេរលំហែកាយ ........ ៨
រូបភាពលេខ០៧៖ ទិដ្ឋភាព នៃការកសាងភូមិ ........ ៩
រូបភាពលេខ០៨៖ ទិដ្ឋភាព នៃការកសាងភូមិ ........ ១០
រូបភាពលេខ០៩៖ ទិដ្ឋភាព នៃការកសាងភូមិ ........ ១០
រូបភាពលេខ១០៖ ផែនទី១៩៥៨ ទស្សនៈទាននៃការរៀបចំទីក្រុងព្រះសីហនុ "កំពង់សោម នាពេលអនាគត" ........ ១១
រូបភាពលេខ១១៖ ផែនទីប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា ឆ្នាំ១៨៩៧ ........ ១៣
រូបភាពលេខ១២៖ ផែនទីប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា ឆ្នាំ១៩០៦ ........ ១៣
រូបភាពលេខ១៣៖ ផ្លូវជាតិលេខ៤ ស្ថាបនានៅក្នុងឆ្នាំ១៩៥៥ ........ ២៣
រូបភាពលេខ១៤៖ កប៉ាល់ដឹកទំនិញខ្នាតតូច (premeier petit cargo) ........ ២៤
រូបភាពលេខ១៥៖ ច្រកផ្លូវចេញចូលនាវា ........ ២៤
រូបភាពលេខ១៦៖ ច្រកផ្លូវចេញចូលនាវា ........ ២៥
រូបភាពលេខ១៧៖ ទិដ្ឋភាពកប៉ាល់ចូលសំចត ........ ២៦
រូបភាពលេខ១៨៖ ផ្លូវដែកពីភ្នំពេញ ទៅក្រុងព្រះសីហនុ សម្រេចបាន ១៦៦ គីឡូម៉ែត្រ ........ ២៦
រូបភាពលេខ១៩៖ ផ្លូវដែកពីភ្នំពេញ ទៅក្រុងព្រះសីហនុ ........ ២៧
រូបភាពលេខ២០៖ ព្រលានយន្តហោះកងកេង ត្រូវបានកសាង នៅក្នុងឆ្នាំ១៩៦០ ........ ២៧
រូបភាពលេខ២១៖ សណ្ឋាគារឯករាជ្យ សាងសង់ នៅទសវត្សឆ្នាំ ១៩៦០ ........ ២៨
រូបភាពលេខ២២៖ ព្រះរាជដំណាក់ ត្រូវបានសាងសង់នៅឆ្នាំ១៩៦០ ........ ២៩
រូបភាពលេខ២៣៖ ស្ថានីយអយស្ម័យយានក្រុងព្រះសីហនុ ........ ២៩
រូបភាពលេខ២៤៖ ការទទួលស្វាគមន៍ សម្តេចនរោត្តម សីហនុ ........ ៣០

រូបភាពលេខ២៥៖ ទិដ្ឋភាពទូទៅ នាស្ថានីយអយស្ម័យយានក្រុងព្រះសីហនុ ............................ ៣០
រូបភាពលេខ២៦៖ រថភ្លើង ចូលចតសំចតនៅក្នុង ស្ថានីយអយស្ម័យយានក្រុងព្រះសីហនុ.............. ៣១
រូបភាពលេខ២៧៖ ស្ថានីយអយស្ម័យយានក្រុងព្រះសីហនុ នាពេលបច្ចុប្បន្ន ............................ ៣១
រូបភាពលេខ២៨៖ រោងចក្រប្រេងកាត ត្រូវបានកសាង នៅក្នុងឆ្នាំ១៩៦៦ ............................... ៣២
រូបភាពលេខ២៩៖ រោងចក្រស្រាបៀរអង្គរ កសាង ពីឆ្នាំ១៩៦៥ ដល់ឆ្នាំ១៩៦៧........................ ៣៣
រូបភាពលេខ៣០៖ សម្ពោធជាផ្លូវការ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៦៨ ក្រោមព្រះរាជអធិបតីភាពរបស់ព្រះបាទ នរោត្តមសីហនុ ............................................................................................ ៣៣
រូបភាពលេខ៣១៖ ធនាគារជាតិ សាខាក្រុងព្រះសីហនុ និងលំនៅដ្ឋានបុគ្គលិក ត្រូវបានសាងសង់ នៅឆ្នាំ១៩៨៦ ............................................................................................................ ៣៤
រូបភាពលេខ៣២៖ ព្រះវិហារកាតូលិក St Michael Church ត្រូវបានសាងសង់ក្នុងឆ្នាំ១៩៦០ ...... ៣៤
រូបភាពលេខ៣៣៖ វត្តជោតញ្ញាណ ( វត្តលើ) ...................................................................... ៣៥
រូបភាពលេខ៣៤៖ វត្តឥន្ទញ្ញាណ (វត្តក្រោម)...................................................................... ៣៥
រូបភាពលេខ៣៥៖ វិមានឯករាជ្យ ត្រូវបានកសាងឡើងនៅក្នុងឆ្នាំ១៩៨៥ ................................. ៣៦
រូបភាពលេខ៣៦៖ វេទិកា ៧មករា ត្រូវបានកសាងឡើងនៅក្នុងឆ្នាំ១៩៨៥ ............................... ៣៦
រូបភាពលេខ៣៧៖ រូបសំណាក់តោពីរ ត្រូវបានកសាងនៅក្នុងឆ្នាំ១៩៩៦ .................................. ៣៧
រូបភាពលេខ៣៨៖ ស្ពានតេជោមរកត ឬ ស្ពានកោះពស់ឆ្លងសមុទ្រ ......................................... ៣៨

**អត្ថបទកំណាព្យ**

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

**ឧបសម្ព័ន្ធទី១៖** សេចក្តីជូនដំណឹងលេខ១៥៦៩ សជណ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ ស្តីពីការសិក្សា ស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់

**ឧបសម្ព័ន្ធទី២៖** សេចក្តីសម្រេចលេខ ០៤១ សសរ/១៣ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ របស់សាលាខេត្តព្រះសីហនុ ស្តីពីការបង្កើតក្រុមការងារ សិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ

**ឧបសម្ព័ន្ធទី៣៖** សេចក្តីសម្រេចលេខ ០៦៧ សសរ/១៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ របស់សាលាខេត្តព្រះសីហនុ ស្តីពី ការបង្កើតក្រុមលេខា នៃក្រុមការងារ សិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ

**ឧបសម្ព័ន្ធទី៤៖** សេចក្តីសម្រេចលេខ១២២/១៦ ស.ស.រ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ១ នៃសេចក្តីសម្រេចលេខ ០៤១សសរ/១៣ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការបង្កើត ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ

**ឧបសម្ព័ន្ធទី៥៖** សេចក្តីសម្រេចលេខ ១២៣/១៦ ស.ស.រ ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលប្រការ១ នៃសេចក្តីសម្រេចលេខ ០៦៧សសរ/១៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ស្តីពីការបង្កើត ក្រុមលេខា នៃក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ

**ផែនទីទេសចរណ៍ខេត្ត**

# ប្រវត្តិខេត្តព្រះសីហនុ

## I. ទិដ្ឋភាពទូទៅ

ខេត្តព្រះសីហនុ ជាខេត្តដែលមានសក្តានុពលសេដ្ឋកិច្ច ( កំពង់ផែស្វយ័ត តំបន់សេដ្ឋកិច្ចពិសេស ព្រលានយន្តហោះ អន្តរជាតិ កងកេង និងឆ្នេរ សមុទ្រ ដ៏ស្រស់ស្អាត) ស្ថិតនៅប៉ែកនិរតី នៃ ប្រទេសកម្ពុជា ជាប់នឹងតំបន់ ឆ្នេរ មាន ចម្ងាយ ២៣០ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ តាមបណ្តោយផ្លូវជាតិ លេខ៤ និង ចម្ងាយ ២៦០ គីឡូម៉ែត្រ តាមបណ្តោយផ្លូវជាតិលេខ ៣ និងមាន ផ្លូវដែកឆ្លង កាត់តាមខេត្តកណ្តាល តាកែវ និងកំពត ហើយមានព្រំប្រទល់៖

-ខាងជើង ជាប់នឹងខេត្តកោះកុង
-ខាងកើត ជាប់នឹងខេត្តកំពត និងខេត្តកំពង់ស្ពឺ
-ខាងត្បូង និងខាងលិច ជាប់នឹងឈូងសមុទ្រថៃឡង់ដ៏

ខេត្តព្រះសីហនុមានផ្ទៃដីសរុប ២,៦៥៨.៩០ គីឡូម៉ែត្រការ៉េ ផ្ទៃដី ២/៣ ជាដីព្រៃភ្នំ និងខ្ពង់រាប មានឆ្នេរសមុទ្រប្រវែង១៧៥.៨១ គីឡូម៉ែត្រ និងមានកោះតូច-ធំ ចំនួន ៣២ កោះ[1] មានដូចជា៖ *(កោះព្រាប កោះពស់ កោះថាស(កោងកាង) កោះដែកគោល កោះត្រេះ(ខ្នះ) កោះរុង កោះបង កោះប្អូន កោះកូន(កុក/កណ្តាល) កោះរុងសន្លឹម កោះមូល កោះតូច កោះប្រើស កោះថ្មី កោះប្រទ្បុះ(ក្របី) កោះតាគៀវ កោះឫស្សី កោះស្រមោច កោះសំពោច កោះសំពោច កោះដូង កោះព្រីង កោះខ្មោច កោះត្រងោល កោះវាល កោះតាង កោះមួយ កោះមួយ កោះដំឡូង(ក្តាម) កោះពីរលិច កោះពីរកើត កោះតា កោះយាយ កោះថៅ)*។ ប្រជុំកោះ ឆ្នេរខ្សាច់ ឆ្នេរថ្ម ឆ្នេរភក់ និងជីវចម្រុះបាតសមុទ្រ បានក្លាយទៅជាគោលដៅ មជ្ឈមណ្ឌល ទេសចរណ៍ធម្មជាតិអន្តរជាតិ ដ៏ពេញនិយម សម្រាប់ទាក់ទាញភ្ញៀវ ទេសចរណ៍ជាតិ-អន្តរជាតិ និងជាប់ជាសមាជិកក្លិបឆ្នេរសមុទ្រ ស្អាតបំផុតលើសកលលោក ដែលប្រសិទ្ធិនាមថា ឆ្នេរសមុទ្រកម្ពុជា " តារាវៈទិសនារតី " ។

ខេត្តព្រះសីហនុ ជាប៉ូលសេដ្ឋកិច្ចមួយ ក្នុងចំណោមប៉ូលសេដ្ឋកិច្ចទាំងបី ក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទីបី របស់រាជរដ្ឋាភិបាលកម្ពុជា និងត្រូវបានកំណត់គោលដៅ ជាតំបន់សេដ្ឋកិច្ចពិសេស ពហុបំណង នៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥ ដោយសារខេត្តមាន សក្តានុពល លើវិស័យទេសចរណ៍ ឧស្សាហកម្ម ពាណិជ្ជកម្ម ។

ខេត្តព្រះសីហនុមាន ០១ ក្រុង និង០៣ ស្រុក ស្មើនឹង ២៣ឃុំ ០៦ សង្កាត់ មាន ១១១ ភូមិ និង មានប្រជាពលរដ្ឋរស់នៅចំនួន ៤៥.០៦៦ គ្រួសារ ចំនួនមនុស្សសរុប ២១១.៥២៦ នាក់ ក្នុងនោះស្ត្រី ១០៧.០៨១ នាក់ ។ ការអភិវឌ្ឍន៍ខេត្តព្រះសីហនុ ត្រូវពឹងផ្អែកលើសក្តានុពល និងធនធានធម្មជាតិ ដែល

[1] *តារាងឈ្មោះកោះ និងទំហំ លេខ២០៣៥ អ.ជនសស/ខសន ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥*

មានស្រាប់ជាចំបង។ បច្ចុប្បន្ន ខេត្តមានស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច ការប្រើប្រាស់ដីធ្លី ការគ្រប់គ្រង ធនធានធម្មជាតិ និងបរិស្ថាន ការគ្រប់គ្រង គ្រោះមហន្តរាយ ការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រង រដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈល្អប្រសើរ [2] ។

## II. ប្រវត្តិនៃការកកើតខេត្ត

ក្រុងកំពង់សោម ដំបូងឡើយ យកឈ្មោះ **ឆកកំពង់សោម** មកដាក់ បន្ទាប់មកបានប្តូរឈ្មោះថា ក្រុងព្រះសីហនុវិញ ដោយយកព្រះនាម សម្តេចព្រះនរោត្តម សីហនុ ដាក់ ព្រោះទីក្រុងនេះ ជាសមិទ្ធផល ក្នុងសម័យព្រះអង្គ ។ ក្រោយរដ្ឋប្រហារ ថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ គេបានដូរឈ្មោះទៅជា ក្រុង កំពង់សោម វិញ [3] ។ ទីក្រុងកំពង់សោម ជាទីក្រុងស្វយ័តមួយ ក្នុងចំណោមទីក្រុងស្វយ័តទាំង២ នៃប្រទេសកម្ពុជាយើង ។ ទីក្រុងនេះមិនត្រឹមតែជាច្រកអន្តរជាតិតាមផ្លូវសមុទ្រ របស់ប្រទេសប៉ុណ្ណោះទេ តែថែមទាំងជាមជ្ឈមណ្ឌលសេដ្ឋកិច្ច យ៉ាងសំខាន់របស់ប្រទេស ថែមទៀតផង ។




រូបភាពលេខ០១៖ ព្រែកកំពង់សោម ដែលហូរចាក់ទៅក្នុងឆកកំពង់សោមដែរនោះ ស្ថិតនៅក្បែរស្រែអំបិល ដោយទទួលទឹកខាងស្តាំដៃពីស្ទឹងកំបុត និងស្ទឹងសំរោង

[2] *សៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៧-២០១៩) ខេត្តព្រះសីហនុ*

[3] *ព្រឹត្តិបត្តិ «ការយល់ដឹងអំពីប្រទេសកម្ពុជា» ចេញផ្សាយនាឆ្នាំ១៩៨៨*

### ១. លក្ខណៈទូទៅរបស់ទីក្រុងកំពង់សោម នៅឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៨៦ ៖

ក្រុងកំពង់សោម ស្ថិតនៅប៉ែកនិរតីនៃប្រទេសកម្ពុជា មានព្រំប្រទល់ខាងកើត ជាប់នឹងខេត្តកំពត ខាងជើងជាប់នឹងខេត្តកោះកុង ខាងលិច និងខាងត្បូងជាប់នឹងសមុទ្រ ។ ផ្ទៃក្រឡាក្រុងកំពង់សោម នៅឆ្នាំ ១៩៦២ គឺគេកំណត់យក ៦៨,២ គីឡូម៉ែត្រការ៉េ ក្រោយមក ដោយការបញ្ចូល ស្រុកព្រៃនប់ នៅក្នុងការគ្រប់គ្រងរបស់ក្រុងទៀតនោះ ផ្ទៃក្រឡារបស់ក្រុង បានពង្រីករហូតដល់ ១.៣០៣ គីឡូម៉ែត្រការ៉េ នាឆ្នាំ ១៩៨៦។

ឆ្នេរសមុទ្រក្រុងកំពង់សោម មានប្រវែង ១០០គីឡូម៉ែត្រ ដែលលាតសន្ធឹង នៅចន្លោះឆ្នេរសមុទ្រខេត្តកោះកុង និងខេត្តកំពត ។ ឆ្នេរនេះ មានសភាពបត់បែនរកេតរកូត បង្កើតបានជាឆក២ គឺឆកកំពង់សោម និងឆកវាលរេញ ។ ឆកកំពង់សោម មានបណ្ដោយ៦០គីឡូម៉ែត្រ និងទទឹង ៣០ គីឡូម៉ែត្រ ។ ឆ្នេរសមុទ្រក្រុងកំពង់សោម ទទួលរបបទឹកសាប ដែលហូរចុះតាមព្រែក ធំៗពីរ គឺព្រែកទឹកសាប និងព្រែកកំពង់ស្មាច់ និងតាមព្រែក តូចៗ ចំនួន៧ផ្សេងទៀត ។

### ២. ឈូងសមុទ្រក្រុងកំពង់សោម៖

ឈូងសមុទ្រក្រុងកំពង់សោម មានបាតរាបស្មើ ជម្រៅទឹកជាមធ្យម ៥០ម៉ែត្រ ជម្រៅជាអតិបរិមាមិនលើសពី ៨០ម៉ែត្រឡើយ។ ឈូងសមុទ្រនេះ ខ័ណ្ឌចែកប្រទេសកម្ពុជា ពីឧបទ្វីបម៉ាឡាកា ។ នៅចំពីមុខឆកកំពង់សោម មានកោះរុង និងកោះរុងសន្លឹម ហើយនៅចំពីមុខកំពង់ផែអន្តរជាតិ មានកោះពស់, កោះដែកគោល, កោះថាស និងកោះព្រាប រីឯនៅចំពីមុខ រាម (មូលដ្ឋានកងនាវាចរណ៍) មានកោះតាគៀវ, កោះឫស្សី, កោះត្រេះ, កោះចន្លុះ និងកោះស្រមោច ។




រូបភាពលេខ០២៖ ឆកកំពង់សោម និងកោះរុង កោះរុងសន្លឹម

## ៣. គំនិតផ្តួចផ្តើម នៃការបង្កើតកំពង់ផែសមុទ្រ៖

នៅមុនសម័យអាណានិគមបារាំង កំពង់ផែកំពត គឺជាច្រកនៃការដឹកជញ្ជូន និងការធ្វើដំណើរតាមផ្លូវសមុទ្ររបស់ប្រទេសកម្ពុជា ក្រោយមក នៅសម័យបារាំង គឺបានបោះបង់លែងប្រើប្រាស់ កំពង់ផែកំពត ហើយគេប្រើប្រាស់ផ្លូវទឹកទន្លេមេគង្គ ចុះទៅកាន់សមុទ្រវិញ ដោយកាត់តាមប្រទេសវៀតណាម ភាគខាងត្បូង ។ នៅដើមសតវត្សទី២០ បារាំង បានយកចិត្តទុកដាក់គិតគូរ ដល់ការបង្កើតច្រកសមុទ្រ តាមតំបន់ឆ្នេររបស់ប្រទេសកម្ពុជាវិញ ព្រោះកន្លងមក បារាំងយកចិត្តទុកដាក់ បង្កើតច្រកសមុទ្រ តែភាគខាងកើតប៉ុណ្ណោះ ដោយចោលឈូងសមុទ្រសៀម ដែលមានផលប្រយោជន៍ដល់បារាំងផងដែរ ។



រូបភាពលេខ០៣៖ ក្រុមការងារវិស្វករចុះសិក្សាស្រាវជ្រាវ ទីតាំងសាងសង់កំពង់ផែ

ឈរលើទស្សនៈខាងលើ បារាំងបានចាប់ផ្ដើមសិក្សាស្រាវជ្រាវ និងស្វែងរកទីតាំង ដើម្បីបង្កើតផែសមុទ្រ នៅប្រទេសកម្ពុជា ហើយការសិក្សាស្រាវជ្រាវនេះ បានរកឃើញ ទីតាំងត្រង់តំបន់ឆកកំពង់សោម។ ប៉ុន្តែដោយសារគ្មានផ្លូវគមនាគមន៍តភ្ជាប់ ដែលទាមទារឱ្យមានការចំណាយថវិកាច្រើន ក្នុងការសាងសង់ផ្លូវគមនាគមន៍ និងកំពង់ផែផងនោះ គម្រោងបង្កើតកំពង់ផែសមុទ្រ ត្រង់ឆកកំពង់សោម ក៏ត្រូវទុកចោលជាបណ្ដោះអាសន្នសិន ព្រោះស្ថានភាពសេដ្ឋកិច្ចនាពេលនោះ មិនអាចធានាដល់ការចំណាយដ៏ច្រើនសន្ធឹកសន្ធាប់នេះបាន ។

បន្ទាប់ពីសង្គ្រាមលោកលើកទី១បានបញ្ចប់ ផែនការបង្កើតច្រក តាមសមុទ្រនៅកម្ពុជានេះ ក៏ត្រូវបានលើកឡើង ម្ដងទៀត ។ ហើយនៅឆ្នាំ១៩២៥ មានការស្ថាបនាផ្លូវពីកំពត ទៅរាម ដែលអាចអនុញ្ញាតឱ្យគេស្ថាបនានូវ ឋបនភណ្ឌ ជាច្រើន នៅកំពង់ផែរាម ។ ការជ្រើសរើសយក រាមនេះ មានអត្ថប្រយោជន៍ពីរ ទីមួយអាចទីតាំងធ្វើកំពង់ផែ និងទីពីរ គេអាចធ្វើផ្លូវគមនាគមន៍ជើងគោក ភ្ជាប់មកតំបន់ផ្ទៃក្នុងប្រទេសបានផងដែរ ។ ប៉ុន្តែជាក់ស្ដែង រាម គ្រាន់តែជាកំពង់ផែដ៏តូច សម្រាប់កងនាវាចរណ៍ ដែលពុំអាចធ្វើអោយមានការរីកចម្រើន ខាងសេដ្ឋកិច្ច និងតំបន់ឆ្នេរសមុទ្រនៃប្រទេសបានទេ ។

គម្រោងនៃការបង្កើតកំពង់ផែថ្មីមួយទៀត ក៏ត្រូវបានសិក្សាស្រាវជ្រាវ ជាបន្តបន្ទាប់ នៅឆ្នាំ១៩៣៧, ១៩៤២ និង១៩៤៨ ប៉ុន្តែ ដោយសារសង្គ្រាម និងការបំផ្លាញផ្លូវពីកំពត ទៅរាម នោះបានកាត់ផ្តាច់មិនឱ្យគម្រោងខាងលើ សម្រេចជារូបរាងឡើយ ។

នៅឆ្នាំ១៩៤៨ កំពង់ផែភ្នំពេញ នៅតែជាកំពង់ផែដ៏ធំមួយ នៃប្រទេសដដែល ។ នៅក្រោយពេលបានឯករាជ្យនាឆ្នាំ១៩៥៣ ភាពចាំបាច់ ដែលត្រូវបង្កើតកំពង់ផែសមុទ្រ នៅលើទឹកដីកម្ពុជា កាន់តែសំខាន់ឡើង ។ ព្រោះការដឹកជញ្ជូនតាមទន្លេមេគង្គ អាចធ្វើបាន តែនាវាដឹកទំនិញធុនមធ្យម ដែលមានបាតចុះទៅក្នុងទឹកជម្រៅមិនហួសពី ៤,១០ ម៉ែត្រ ។ ការបង្កើតកំពង់ផែ ដែលអាចឱ្យកប៉ាល់ដឹកជញ្ជូន ធំៗ ចូលចតដូចជាកប៉ាល់ដឹកប្រេងជាដើម ទាមទារឱ្យរដ្ឋាភិបាល ត្រូវតែធ្វើការសម្រេច ពីបញ្ហានេះជាបន្ទាន់ បន្ទាប់ពីបានឯករាជ្យ ។ នៅដើមឆ្នាំ១៩៥៤ រាជរដ្ឋាភិបាល បានសម្រេច ឱ្យស្ថាបនាកំពង់ផែសមុទ្រមួយ ដែលអាចឱ្យនាវាដឹកជញ្ជូន ធំៗចូលចតបាន ។

### ៤. ការជ្រើសរើសទីតាំង កំពង់ផែសមុទ្រៈ

បន្ទាប់ពីការសិក្សា ក្នុងការជ្រើសរើសទីតាំងកំពង់ផែសមុទ្រនេះ គេមើលឃើញទីតាំង ពីរកន្លែងដែលមានជម្រៅទឹកប្រហែល ១០ ម៉ែត្រ។ កន្លែងទី១ ស្ថិតនៅប៉ែកអាគ្នេយ៍ នៃឆកកំពង់សោម ជិតកោះពស់ (ត្រង់ទីតាំងសព្វថ្ងៃ) និងទីកន្លែងមួយទៀត ស្ថិតនៅប៉ែកនិរតីនៃឆកកំពង់សោម ដោយគេមិនជ្រើសរើសយកតំបន់ រាម ទេ ព្រោះទីកន្លែងនោះមានជម្រៅទឹករាក់ពេក (ប្រហែល៦ម៉ែត្រ) ហើយគេក៏មិនជ្រើសយកតំបន់ឆ្នេររាបស្មើ ពីរាម ទៅដល់ព្រំដែនប្រទេសវៀតណាមដែរ ។ ដោយមូលហេតុពិបាកធ្វើដំណើរទៅដល់ គេក៏មិនរុករកទីកន្លែង សម្រាប់សង់កំពង់ផែ នៅតាមឆ្នេរភាគខាងលិច ដែលលាតសន្ធឹង ទៅដល់ព្រំប្រទល់ប្រទេសថៃនោះទេ។

ការសម្រេចជាចុងក្រោយ គេបានបោះបង់ចោលកន្លែងទី២ គឺភាគខាងនិរតីឆកកំពង់សោម ដោយគេជ្រើសរើសទីតាំងសម្រាប់ សាងសង់កំពង់ផែនោះ គឺភាគអាគ្នេយ៍ នៃឆក កំពង់សោម ជិតកោះពស់វិញ ដោយសារកន្លែងនោះ អំណោយផលសម្រាប់ការសាងសង់ និងមានជម្រៅទឹកជ្រៅ មិនចាំបាច់បូមខ្សាច់សមុទ្រ រឺកាយដីចេញនោះទេ ។



រូបភាពលេខ០៤៖ ទីតាំងឆ្នេរនៅខាងមុខកោះពស់

បន្ទាប់ពីថតរូបទីកន្លែងខាងលើ ពីលើយន្តហោះ នៅខែឧសភា ១៩៥៥ បានអោយដឹងថា តំបន់ឆ្នេរនេះ ជាតំបន់មួយ ដែលមានព្រៃក្រាស់ រហូតដល់មាត់ច្រាំង ហើយពុំមានមនុស្សចូលទៅដល់ឡើយ ។ ថ្វីបើតំបន់នេះ មានការលំបាក ក្នុងការធ្វើដំណើរទៅដល់ក៏ដោយ តែទីតាំងនេះ គឺជាទីតាំងអំណោយផលជាងកន្លែងដទៃទៀត ក្នុងការសាងសង់កំពង់ផែ ដោយសារមានជម្រៅទឹកជ្រៅ ដែលធ្វើអោយ ការចូលចតរបស់កប៉ាល់ ឬនាវា មានភាពងាយស្រួល គ្រប់ពេល និងគ្រប់រដូវ ហើយមានចម្ងាយពីភ្នំពេញ ជិតជាងកន្លែងផ្សេងទៀត ។ លើសពីនេះ តាមការសិក្សា និងការពិនិត្យមើលជារួម នៅទីតាំងនេះ អាចមានលទ្ធភាពក្នុងការពង្រីកនូវកំពង់ផែ ទៅថ្ងៃក្រោយទៀត ប្រសិនបើមានភាពចាំបាច់ ដែលស្របតាមការរីកចម្រើនរបស់ប្រទេសជាតិ ។



រូបភាពលេខ០៥៖ ទីតាំងឆ្នេរនៅទល់មុខកោះពស់ (ឆ្នេរលំហែកាយ)

នៅពីមុខតំបន់ដែលត្រូវសង់កំពង់ផែនោះ គឺមានកោះពស់ ដែលជារបាំង អាចការពារខ្យល់ព្យុះបាន ហើយនៅចន្លោះកោះពស់ និងឆ្នេរ មានជម្រៅទឹក សម្រាប់ផ្លូវកប៉ាល់ចូលមានពី ១១ទៅ ១៣ម៉ែត្រ លើកលែងកន្លែងដែលមានថ្ម គឺមានជម្រៅ ៨,៤ ម៉ែត្រ ដូច្នេះកប៉ាល់ អាចចេញចូលមក កំពង់ផែបាន ។



រូបភាពលេខ០៦៖ គន្លងទឹកនៅចន្លោះកោះពស់ និងឆ្នេរលំហែកាយ

ដោយសារការរីកចំរើននៃតំបន់នេះ គេសង្កេតឃើញ មានការសាងសង់គេហដ្ឋានសំរាប់កម្មករ និង បុគ្គលិកធ្វើការកំពង់ផែស្នាក់នៅ ត្រង់ទីឆ្លាភាគខាងត្បូងនៃកំពង់ផែ ហើយ ទីក្រុងមួយ ក៏ត្រូវបានលេច ចេញជារូបរាងឡើង ស្ថិតក្នុងតំបន់ កំពង់ផែ កំពង់សោម នាឆ្នាំ១៩៥៧ ដោយកាត់ដីមួយផ្នែកពីខេត្តកំពត គឺឃុំរាម [4] ដែលទីតាំងនេះ ពីដើមជាភូមិនេសាទមួយ ចំណុះអោយឃុំរាម ខណ្ឌព្រៃនប់ ស្រុកកំពត ខេត្ត កំពត។ ខណ្ឌព្រៃនប់ នាសម័យកាលនោះ មានឃុំចំណុះចំនួន ៥ គឺឃុំរាម ឃុំសំរ៉ុង ឃុំស្រែចាម ឃុំទឹកល្អក់ និងឃុំវាលរេញ[5] ។



រូបភាពលេខ០៧៖ ទិដ្ឋភាព នៃការកសាងភូមិ

[4] *ព្រះរាជក្រមលេខ ២៣៦ - ន.ស ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ១៩៥៧ ស្តីពីការបង្កើតទីក្រុងកំពង់សោម*

[5] *យោងព្រះរាជប្រកាសលេខ៥២ ចុះថ្ងៃ១៤រោជ ខែទុតិយាសាធ ឆ្នាំកុរ បញ្ចស័ក្ស ត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ១៩២៣ ដែលមានប្រកាស អាររេតេលោក ឡឺរេស៊ីដង្ក សុប៉េរីយ៉េរ លេខ ១៦៤០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩២៣ ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា*



រូបភាពលេខ០៨៖ ទិដ្ឋភាព នៃការកសាងភូមិ



រូបភាពលេខ០៩៖ ទិដ្ឋភាព នៃការកសាងភូមិ




រូបភាពលេខ១០៖ ផែនទី១៩៥៨ ទស្សនៈទាននៃការរៀបចំទីក្រុងព្រះសីហនុ "កំពង់សោម នាពេលអនាគត"

## ៥. មូលហេតុដែលដាក់ឈ្មោះ តំបន់នេះថា កំពង់សោម៖

កាលដើមឡើយ កំពង់សោម មានទីតាំងស្ថិតនៅក្នុងស្រុកស្រែអំបិល ខេត្តកោះកុង ។ បើតាម លោក សាន សុមែន ដែលធ្លាប់ធ្វើជា គ្រូពុទ្ធិកបឋមសិក្សាវត្តឥន្ទញាណ (ក្រុងព្រះសីហនុ) បានលើកឡើង ថា លោកបានសាកសួរចាស់ៗ ដែលរស់នៅ ស្រុកព្រៃនប់ បានបញ្ជាក់ឱ្យដឹង កំពង់សោម មានពីរ គឺកំពង់ សោមលើ ស្ថិតនៅភូមិចំប៉ា (ស្រុកកំពង់សិលា) និង កំពង់សោមក្រោម ស្ថិតនៅក្នុង ស្រុកស្រែអំបិល ។

លោក សាន សុមែន បានមានប្រសាសន៍បន្ថែមទៀតថា បើយោងតាមប្រសាសន៍ របស់លោកតា អាចារ្យ ម៉ុល សុខ ជាចាស់ទុំធ្លាប់រស់នៅស្រុកព្រៃនប់បានឱ្យដឹងថា បានជាគេហៅថា កំពង់សោម ព្រោះ មានប្រវត្តិដំណាលមកថា កាលពីដើមឡើយ ស្រុកស្រែអំបិល ដែលស្ថិតនៅក្នុង ខេត្តកោះកុង សព្វថ្ងៃនេះ មានឈូងសមុទ្រមួយលាតសន្ធឹងពី ស្រុកស្រែអំបិល រហូតមកដល់ ក្រុងព្រះសីហនុ បច្ចុប្បន្ន ដែលទីនោះ មានព្រៃកោងកាង និងព្រៃឈើគ្រប់ប្រភេទ ហើយសម្បូរទៅដោយ ផ្កាសោម ព្រមទាំងមានសត្វម្រឹគ កាច សាហាវ យ៉ាងច្រើន ដូចជាសត្វខ្លា ដំរី ជាដើម ។ រីឯប្រជាជនដែលរស់នៅទីនោះ មានចំនួនតិចតួចណាស់

ដោយប្រកបរបរចិញ្ចឹមជីវិត គឺឡើងភ្នំ និងចុះសមុទ្រនេសាទ ។ ក្រៅពីរបរនេសាទ ប្រជាជន ក៏បានទៅកាប់ផ្តៅសោម អូសបណ្តែតតាមទឹក ហើយឡើងនៅកំពង់ផែត្រពាំង (ឃុំស្រែអំបិលបច្ចុប្បន្ន) ។ តាមប្រសាសន៍ របស់លោកតាអាចារ្យដដែល បានឱ្យដឹងថា ទីនោះសម្បូរទៅដោយផ្តៅសោមណាស់ ដោយគេកាប់យកស្លឹកវាមកប្រក់ផ្ទះសម្បែងរបស់ពួកគេ ។ ឯការអូសផ្តៅសោម មកចតនៅមាត់កំពង់ នេះជារៀងរាល់ពេលទៅ ទើបគេហៅទីនេះថា កំពង់ផ្តៅសោម ។ ទាំងអ្នកនេសាទ និងអ្នកដែល ទៅកាប់ផ្តៅនៅទីនោះ គេតែងតែហៅតំបន់នោះថា កំពង់ផ្តៅសោម ហើយក្រោយមក ហៅកាត់ថា កំពង់សោម។ ចំណែកអ្នកនៅស្រុកខាងកើតដូចជាខាងខេត្តកំពង់ស្ពឺ ជាដើម បើកាលណាគេចង់មកស្រុកខាងលិច គេតែងនិយាយថា **"យើងនាំគ្នាទៅកំពង់សោមៗ (ក្នុងស្រុកស្រែអំបិលហ្នឹងឯង)"** ។

លោក សាន សុមែន បានបញ្ជាក់បន្ថែមថា តាមប្រសាសន៍ របស់ចាស់ទុំមួយចំនួន ដែលជាមនុស្សរស់នៅតំបន់នេះ តាំងពីដើមឡើយបានឱ្យដឹងថា ទីនេះ កាលពីមុនគេហៅថា តំបន់ភ្នំថ្មរាប ឬតំបន់កោះពស់ ។ ក្នុងសម័យ ដែលគេហៅថា តំបន់ភ្នំថ្មរាប ឬតំបន់កោះពស់នោះ គឺជាសម័យ ដែលទឹកដី ខេត្តកោះកុង និងកំពង់សោម ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខេត្តកំពត ។

បើយោងតាមឯកសារស្រាវជ្រាវមួយចំនួន បានលើកឡើងថា មូលហេតុដែលដាក់ឈ្មោះតំបន់នេះថា កំពង់សោម គឺយកឈ្មោះតាម ឆកសមុទ្រ កំពង់សោម មកដាក់ ។

## III. ការកែសម្រួលព្រំប្រទល់ និងការប្តូរឈ្មោះខេត្ត

ការវិវត្តន៍ នៃការគ្រប់គ្រង ពីសម័យកាលមួយទៅសម័យកាល ធ្វើការអោយមានការកែសម្រួលព្រំប្រទល់ ក៏ដូចជាការបំបែកចេញ និងការរួមបញ្ចូលគ្នានូវ ខេត្ត ស្រុក ខណ្ឌ ឃុំមួយចំនួន ជាដើម ក្នុងនោះផងដែរ ទឹកដីនៃខេត្តព្រះសីហនុ ពីដើមឡើយ គឺស្ថិតក្រោមការគ្រប់គ្រងរបស់ខេត្តកំពត ។




រូបភាពលេខ១១៖ ផែនទីប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា ឆ្នាំ១៨៩៧




រូបភាពលេខ១២៖ ផែនទីប្រវត្តិសាស្ត្រ ប្រទេសកម្ពុជា ឆ្នាំ១៩០៦

### ១. មណ្ឌលរ៉េស៊ីដង់កំពត ត្រូវបង្កើតអោយទៅជាខេត្តតែមួយ ដោយដាក់ឈ្មោះថា ខេត្ត កំពត មានទីតាំងនៅកំពត ស្ថាក់ការធ្វើការនៅនិវេសដ្ឋានរ៉េស៊ីដង់៖

នៅឆ្នាំ១៩២៣ ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះស៊ីសុវត្ថិ [6] កំពត ត្រូវបានបង្កើតអោយទៅជាខេត្តតែមួយ ដែលមានស្រុកចំណុះ ចំនួនបី គឺ ១. ស្រុកកំពត មានទីតាំងនៅកំពត ដែលបង្កើតឡើង ដោយរួមបញ្ចូលខេត្តកំពត និងខេត្តកំពង់សោម។ ២. ខេត្តបន្ទាយមាស សព្វថ្ងៃត្រូវទុកជាស្រុកបន្ទាយមាស មានទីតាំងនៅទូកមាស។ ៣. ខេត្តកោះកុង សព្វថ្ងៃត្រូវទុកជាស្រុកកោះកុង មានទីតាំងនៅកោះក្រពិ។ ស្រុកកំពត បន្ទាយមាស និងកោះកុង ត្រូវចែកចេញជាខ័ណ្ឌ និងឃុំចំណុះ ដូចខាងក្រោម៖

**១.១. ស្រុកកំពត មានខ័ណ្ឌ ៤**

**១.១.១. ខ័ណ្ឌកំពត មានទីតាំងនៅកំពត មាន ១៥ ឃុំ៖**

១. កណ្តោល ២. បឹងព្រះ ៣. ចក្រីទីង ៤. កំពត ៥. កោះតូច ៦. កូនសត្វ ៧. កែប ៨. ក្បាលរមាស ៩. កំពង់នង់ ១០. សង់កុល ១១. ស្នាមអំពិល ១២. ស្ទឹងកែវ ១៣. តាដិប ១៤. ត្រពាំងធំ ១៥. ព្រៃកោស ។

**១.១.២. ខ័ណ្ឌឈូក មានទីតាំងនៅឈូក មាន ១០ ឃុំ៖**

១. បានៀវ ២. បឹងស្រងែរ ៣. ឈូក ៤. ក្រាំងស្បូវ ៥. ក្រាំងស្នាយ ៦. ល្បើក ៧. ពពេល ពក ៨. រវៀង ៩. ស្រែក្នុង ១០. ត្រពាំងរាំង ។

**១.១.៣. ខ័ណ្ឌព្រៃនប់ មានទីតាំងនៅសំរោង (សំរ៉ុង) មាន ៥ ឃុំ៖**

១. រាម ២. សំរោង (សំរ៉ុង) ៣. ស្រែចាម ៤. ទឹកល្អក់ ៥. វាលរេញ ។

**១.១.៤. ខ័ណ្ឌកំពង់សោម មានទីតាំងនៅត្រពាំង មាន ១១ ឃុំ៖**

១. ដីខា ២. ដីម៉ាល ៣. ដីផាត់ ៤. ដងពេង ៥. កំពង់សោមលើ ៦. ក្រំពុក ៧. ពកបេង ៨. ព្រលាន ៩. សូអ៊ុយ ១០. ថ្មស ១១. ត្រពាំង (ស្រែអំបិល) ។

**១.២. ស្រុកបន្ទាយមាស មានខ័ណ្ឌ ៣**

**១.២.១. ខ័ណ្ឌបន្ទាយមាស មានទីតាំងនៅទូកមាស មាន ១០ ឃុំ៖**

*[6] ព្រះរាជប្រកាសលេខ៥២ ចុះថ្ងៃ១៤រោជ ខែទុតិយាសាធ ឆ្នាំកុរ បញ្ចស័ក្ស ត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ១៩២៣ ដែលមានប្រកាសអាររេតេលោក ឡឺរេស៊ីដង្ក សុប៉េរីយើរ លេខ ១៦៤០ ចុះថ្ងៃ ២០ អ៊ូត ១៩២៣ ក្នុងរជ្ជកាលព្រះបាទសម្តេចព្រះស៊ីសុវត្ថិ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា*

១. បន្ទាយមាស ២. ប្រាប ៣. ដំបូកខ្ពស់ ៤. ខ្នាច ៥. សំពោង ៦. ស្តេចគង់ ៧. ទូកមាស ៨. ត្នោតចុងស្រង់ ៩. ត្រពាំងត្នោត ១០. វត្តអង្គ ។

**១.២.២. ខ័ណ្ឌកំពង់ត្រាច មានទីតាំងនៅកំពង់ត្រាច មាន ១១ ឃុំ៖**

១. បឹងសាលា ២. ដំណាក់កន្ទួត ៣. កន្ថោរ ៤. កោះចន្ទុះ ៥. កំពង់ត្រាច ៦. ភ្នំលាវ ៧. ព្រែកត្រើស ៨. បេងក្រាស ៩. ឫស្សីស្រុក ១០. ស្វាយទង ១១. ស្រែជា ។

**១.២.៣. ខ័ណ្ឌតានី មានទីតាំងនៅភ្នំកុង មាន ៨ ឃុំ៖**

១. អង្គរជ័យ ២. ម្រោម ៣. ភ្នំកុង ៤. ប្រភ្នំ ៥. សំឡាញ ៦. ត្នោត ៧. ត្រពាំខ្សុង ៨. ត្រពាំងរុន ។

## ១.៣. ស្រុកកោះកុង មានខ័ណ្ឌ ២

**១.៣.១. ខ័ណ្ឌឡាំដាំ មានទីតាំងនៅកោះក្រពិ មាន ៨ ឃុំ៖**

១. អានី ២. បឹងក្រសោប ៣. កោះក្រពិ ៤. គោកពោ ៥. ប៉ាកខ្លង ៦. ព្រែកខ្សាច់ ៧. តាតៃ ៨. ត្រពាំងរូង ។

**១.៣.២. ខ័ណ្ឌជំនាប មានទីតាំងនៅជំនាប មាន ៥ ឃុំ៖**

១. ចំណា ២. ជំនាប ៣. ប្រឡាយ ៤. ឫស្សីជ្រុំ ៥. តាតី ។

## ២. ការកែសម្រួល ស្រុកធំៗទាំងបី ដែលចំណុះខេត្តកំពត ទៅជាប្រាំពីរស្រុក៖

ក្រោយមកនៅឆ្នាំ១៩៣៥ ខេត្តកំពត ត្រូវបានកែសម្រួលពីស្រុកធំៗទាំងបី ទៅជាប្រាំពីរស្រុក [7] មានដូចជា៖

**២.១. ស្រុកកំពត មានទីតាំងនៅកំពត មាន ១៤ ឃុំ៖**

១. កណ្តោល ២. ចក្រីទីង ៣. កំពត ៤. កោះតូច ៥. កូនសត្វ ៦. ក្បាលរមាស ៧. កំពង់នង់ ៨. សង់កុល ៩. ស្ទឹងកែវ ១០. រាម ១១. សំពោង (សំរ៉ុង) ១២. ស្រែចាម ១៣. ទឹកល្អក់ ១៤. វាលរេញ ។

**២.២. ស្រុកឈូក មានទីតាំងនៅឈូក មាន ១០ ឃុំ៖**

[7] *ព្រះរាជប្រកាសលេខ ២២ ចុះថ្ងៃទី ៩ រោជ ខែបុស្ស ឆ្នាំ ច ឆស័ក ព.ស ២៤៧៧ ត្រូវនឹងថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៣៥*

១. បានៀវ ២. បឹងស្រង៉ែ ៣. ឈូក ៤. ក្រាំងស្បូវ ៥. ក្រាំងស្នាយ ៦. ល្មើក
៧. ពពេលពក ៨. ស្រែក្នុង ៩. ត្រពាំងរាំង ១០. តាកែន ។

**២.៣. ស្រុកកំពង់សោម មានទីតាំងនៅត្រពាំង មាន ៧ ឃុំ៖**

១. ជីខោ ២. ជីផាត់ ៣. កំពង់សោមលើ ៤. ដងពេង ៥. ពោបេង ៦. ថ្មសរ
៧. ត្រពាំង(ស្រុកស្រែអំបិលសព្វថ្ងៃ) ។

**២.៤. ស្រុកបន្ទាយមាស មានទីតាំងនៅបន្ទាយមាស មាន ១៣ ឃុំ៖**

១. បន្ទាយមាស ២. ដំបូកខ្ពស់ ៣. ខ្ចាយ ៤. សំរោង ៥. ស្តេចគង់ ៦. ទូកមាស
៧. ត្នោតចុងស្រង់ ៨. វត្តអង្គ ៩. អង្គរជ័យ ១០. មរោម ១១. ភ្នំកុង ១២. ព្រះភ្នំ
១៣. សំឡាញ ។

**២.៥. ស្រុកកំពង់ត្រាច មានទីតាំងនៅកំពង់ត្រាច មាន ៩ ឃុំ៖**

១. បឹងសាលា ២. ដំណាក់កន្ទួត ៣. កន្ថោរ ៤. កំពង់ត្រាច ៥. ភ្នំលាវ ៦. ព្រែកក្រើស
៧. ឬស្សីស្រុក ៨. ស្វាយទង ៩. ស្រែជា ។

**២.៦. ស្រុកកោះកុង មានទីតាំងនៅកោះក្រពិ មាន ៦ ឃុំ៖**

១. ព្រែកខ្សាច់ ២. បឹងក្រសោប ៣. កោះក្រពិ ៤. កោះពោរ ៥. ភាតាយ ៦. ត្រពាំងរូង ។

**២.៧. ស្រុកជំនាប មានទីតាំងនៅជំនាប មាន ៤ ឃុំ៖**

១. ជំនាប ២. ប្រឡាយ ៣. ឬស្សីជ្រំ ៤. តាឡៃ ។

## ៣. ការបង្កើតទីក្រុង កំពង់សោម

នៅក្នុងឆ្នាំ១៩៥៦ មានការស្ថាបនាកំពង់ផែ នៅតំបន់កោះពស់ (កំពង់សោម) ស្ថិតនៅឃុំរាម ខណ្ឌព្រៃនប់ ស្រុកកំពត ខេត្តកំពត ដោយតែការរីកចម្រើននៃតំបន់នេះ ទើបនៅឆ្នាំ១៩៥៧ តំបន់នេះត្រូវបាន បង្កើតជាទីក្រុង ដែលមានឈ្មោះថា ក្រុងកំពង់សោម ដោយហ្លួងសុរាម្រឹត ។

## ៤. ការប្តូរឈ្មោះ ក្រុងកំពង់សោម ទៅជាក្រុងព្រះសីហនុ

ក្រោយមកនៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៥៩ ក្នុងរជ្ជកាល ព្រះបាទសម្តេច ព្រះនរោត្តមសុរាម្រិត្យ បានសម្រេច បង្កើតអោយមានទីក្រុមមឿងមួយ ហៅថា "ក្រុងព្រះសីហនុ" នៅឃុំរាម ក្នុងតំបន់ផែកំពង់សោម ដោយក្រុងកំពង់សោម ត្រូវបានប្តូរឈ្មោះ ទៅជាក្រុងព្រះសីហនុវិញ [8] ។

## ៥. ក្រុងព្រះសីហនុ ត្រូវបានតំឡើងឋានៈជារាជធានីទី២

ហើយនៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៦៤ ក្រុងព្រះសីហនុ ត្រូវបានតំឡើងឋានៈជារាជធានីទី២ នៃព្រះរាជាណាចក្រកម្ពុជា [9] ។ ចាប់ពីពេលនោះមក សកម្មភាពសាងសង់មានជាហូរហែរ ដូចជារោងចក្រស្រាបៀរអង្គរ រោងចក្រតម្លើងរថយន្តអង្គរ សណ្ឋាគារឯករាជ្យ ។ល។ ខណៈនោះក្រុងព្រះសីហនុ មិនទាន់ល្បីល្បាញខាងទេសចរណ៍ប៉ុន្មានទេ គឺពេលសំរាកលំហែកាយ គេច្រើននាំគ្នាទៅទីក្រុងកែប។ ក្រោយមកវិស័យទេសចរណ៍ក៏រីកចំរើន ដោយសារក្រុងព្រះសីហនុ មានឆ្នេរខ្សាច់ល្អស្អាត ខ្យល់អាកាសបរិសុទ្ធ និងទេសភាពស្រស់ត្រកាល។

## ៦. ក្រុងព្រះសីហនុ ត្រូវបានប្តូរឈ្មោះមក ក្រុងកំពង់សោម វិញ

ក្រោយពីរដ្ឋប្រហារ លន់ នល់ នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ក្រុងព្រះសីហនុ ត្រូវបានផ្លាស់ប្តូរឈ្មោះទៅជា ក្រុងកំពង់សោមវិញ[10] ។ ពីឆ្នាំ ១៩៧០ ដល់ ១៩៧៥ កំពង់ផែ មានសកម្មភាព រអាក់រអួលខ្លះ ដោយសារសង្គ្រាម។

---

*[8] ព្រះរាជក្រមលេខ ២៩៦-ន.ស. ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៥៩ ស្តីពីការផ្លាស់ឈ្មោះ ក្រុងកំពង់សោម ជាក្រុងព្រះសីហនុ ដោយរដ្ឋសភាបានអនុម័តនាថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៥៩*

*[9] ច្បាប់ស្តីពីការតំឡើងឋានៈអោយក្រុងព្រះសីហនុជារាជធានីទី២" ដែលមានចែង នៅក្នុងមាត្រាតែមួយ - ក្រុងព្រះសីហនុ ត្រូវតំឡើងឋានៈជារាជធានីទី២ នៃព្រះរាជាណាចក្រកម្ពុជា។*

*[10] ច្បាប់ដែលរដ្ឋសភា បានអនុម័តលើកទី១ កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧០ មានសេចក្តីដូចតទៅ៖ "ច្បាប់ស្តីពី ការប្តូរនាម ក្រុងព្រះសីហនុ ក្រុងជូឡុង និងក្រុងខេមរភូមិន្ទ" ។ មាត្រា១ - ក្រុងព្រះសីហនុ ក្រុងជូឡុង និងក្រុងខេមរភូមិន្ទ ត្រូវមាននាមថ្មី ជាក្រុងកំពង់សោម ក្រុងគិរីរម្យ និងក្រុងកោះកុង។*

## ៧. ក្រុងកំពង់សោម ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

ចាប់ពី ឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យ សម័យ ប៉ុល ពត "ខ្មែរក្រហម" ក្រុងកំពង់សោម មិនមានការផ្លាស់ប្តូរឈ្មោះទេ ហើយពេលនោះ កំពង់ផែ មានសកម្មភាពលើកដាក់មួយចំនួនផងដែរ។

## ៨. ដំណាក់កាល ស្តារ និងអភិវឌ្ឍន៍ ក្រុងកំពង់សោម

ចាប់ពីឆ្នាំ ១៩៧៩ មកដល់បច្ចុប្បន្ននេះ ជាដំណាក់កាល ស្តារ និងអភិវឌ្ឍន៍ ក្រុងកំពង់សោម ឡើងវិញ បន្ទាប់ពីថ្ងៃរំដោះ ៧ មករា ១៩៧៩។

## ៩. បង្កើតខណ្ឌចំណុះ ក្រុងកំពង់សោម

ខណ្ឌស្ទឹងហាវ ត្រូវបានបង្កើតចំណុះឱ្យក្រុងកំពង់សោម នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៨៥ មានបីសង្កាត់ (សង្កាត់កំពេញ សង្កាត់ទំនប់រលក និងសង្កាត់អូរត្រេះ) [11] ។

ខណ្ឌមិត្តភាព ត្រូវបានបង្កើតចំណុះឱ្យក្រុងកំពង់សោម នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៨៧ មានបួនសង្កាត់ (សង្កាត់លេខ១ សង្កាត់លេខ២ សង្កាត់លេខ៣ និងសង្កាត់លេខ៤) [12] ។

## ១០. ក្រុងកំពង់សោម ត្រូវបានប្តូរឈ្មោះ ទៅជាក្រុងព្រះសីហនុ វិញ

ហេតុមកដល់ ឆ្នាំ ១៩៩៣ ក្រោយពីខ្មែរបានរួបរួមគ្នាឡើងវិញ ក្រុងកំពង់សោម ត្រូវបានប្តូរឈ្មោះមកជាក្រុងព្រះសីហនុ វិញ។

## ១១. ក្រុងព្រះសីហនុ ត្រូវប្តូរមកជា ខេត្តព្រះសីហនុ

នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨ ក្រុងព្រះសីហនុ ត្រូវប្តូរមកជា ខេត្តព្រះសីហនុ ដោយបានកាត់ដីស្រុក កំពង់សីលា ចេញពីខេត្តកោះកុង មកខេត្តព្រះសីហនុ [13] ។

---

[11] *អនុក្រិត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៨៥ ស្តីពីការបង្កើតខណ្ឌស្ទឹងហាវ*

[12] *អនុក្រិត្យលេខ ២៧ អ.ន.ក្រ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៨៧ ស្តីពីការបង្កើតខណ្ឌមិត្តភាព*

[13] *ព្រះរាជក្រិត្យ នស/រកត/១២០៨/១៣៨៥ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការប្តូរឈ្មោះក្រុងព្រះសីហនុ មកជា ខេត្តព្រះសីហនុ*

## ១២. កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ ៖

កំណែទម្រង់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការអនុវត្តច្បាប់រៀបចំអង្គការ សម្រាប់គ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវបានរដ្ឋសភាអនុម័ត នៅខែ មេសា ឆ្នាំ២០០៨ និងប្រកាសអោយប្រើនៅខែឧសភា ឆ្នាំ២០០៨។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គឺមានគោលបំណង លើកកម្ពស់អភិបាលកិច្ចតាមបែបប្រជាធិបតេយ្យ តាមរយៈ វិមជ្ឈការ និងវិសហមជ្ឈការ សំដៅអោយរដ្ឋបាលថ្នាក់ក្រោមជាតិចូលរួមអោយបានកាន់តែទូលំទូលាយ និងមានប្រសិទ្ធិភាពខ្ពស់ ក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រទេស ជាតិ។

ជាមួយគ្នានេះ ក៏ត្រូវកំណត់តំបន់ទីប្រជុំជន ក៏ដូចជាតំបន់ក្រៅទីប្រជុំជនទៅតាមការរីកចំរើន នៃការអភិវឌ្ឍរបស់រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ។ ដូច្នេះហើយ ទើបរាជរដ្ឋាភិបាល រៀបចំអោយមាន ការកែសម្រួលព្រំប្រទល់រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងប្តូរឈ្មោះក្រុង អោយទៅជាខេត្ត ដើម្បីរៀបចំរចនាសម្ព័ន្ធ និងការគ្រប់គ្រងរដ្ឋបាល អោយស្រប តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ជាក់ស្តែងអតីតក្រុងព្រះសីហនុ ត្រូវបានកែសម្រួលព្រំប្រទល់រដ្ឋបាល រវាងក្រុងព្រះសីហនុ និងខេត្តកោះកុង ដោយកាត់យក ស្រុកកំពង់សីលាទាំងមូល និងដីធ្លីមួយផ្នែកនៃស្រុកស្រែអំបិល ខេត្តកោះកុង អោយមកក្រុងព្រះសីហនុ។

បន្ទាប់ពីរៀបចំ កែសម្រួលព្រំប្រទល់ រដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួចរាល់ រាជរដ្ឋាភិបាលកម្ពុជា បានកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី១ [14] ក្នុងនោះខេត្តព្រះសីហនុមានចំនួនក្រុមប្រឹក្សា ១៥ នាក់ និង ក្នុងនោះ ខេត្តព្រះសីហនុ មានគណៈអភិបាលខេត្ត ចំនួន ៦នាក់ [15] ។ បន្ទាប់ពីបានកំណត់ចំនួនក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរួចមក រាជរដ្ឋាភិបាលបានកំណត់កាលបរិច្ឆេទ សម្រាប់បោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (បោះឆ្នោតសកល) នៅថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០០៩។

---

*[14] អនុក្រឹត្យ លេខ១៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្តីពីកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី១*

*[15] អនុក្រឹត្យ លេខ២៦ អនក្រ. បកចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាល រាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ*

បន្ទាប់ពីមាន ការសម្រួលព្រំប្រទល់រដ្ឋបាល រវាងក្រុងព្រះសីហនុ និងខេត្តកោះកុងលើកទី១ ក៏មាន ការសម្រួលព្រំប្រទល់រដ្ឋបាល រវាងខេត្តព្រះសីហនុ និងខេត្តកោះកុងលើកទី២ ដោយកាត់យកផ្ទៃដីមួយផ្នែក ពីភូមិនេសាទ នៃឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង មកបញ្ចូលក្នុងភូមិកែវផុស នៃឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ [16] ។

## ១៣. បង្កើតឃុំកែវផុស ចំណុះឱ្យ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

ក្រោយពីមាន ការសម្រួលព្រំប្រទល់រដ្ឋបាល រវាងខេត្តព្រះសីហនុ និងខេត្តកោះកុងរួចមក រាជរដ្ឋាភិបាល បានបង្កើតឃុំថ្មីមួយបន្ថែមទៀត គឺឃុំកែវផុស នៃស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដោយកាត់យកភូមិចំនួន០៣ ពីឃុំទំនប់រលក នៃស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ គឺភូមិកែវផុស ភូមិឫទ្ធី១ និងភូមិឫទ្ធី២ និងកាត់យកដីមួយផ្នែកពីឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ [17] ។ សូមបញ្ជាក់បន្ថែមថា ភូមិចំនួន០៣ គឺភូមិកែវផុស ភូមិឫទ្ធី១ និងភូមិឫទ្ធី២ ដែលកាត់យកពីឃុំទំនប់រលកនេះ គឺអតីតជាភូមិកែវផុស នៃឃុំទំនប់រលក ដែលបានបំបែកជា០៣ភូមិ គឺភូមិកែវផុស ភូមិឫទ្ធី១ និងភូមិឫទ្ធី២ [18] ។

## ១៤. បង្កើតឃុំតានៃ ចំណុះឱ្យ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជា ដែលមានសម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ បានសម្រេច ៖

-បង្កើត ឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដោយកាត់យកភូមិចំនួន០៥ នៃឃុំជើងគោ គឺភូមិតាពៅ ភូមិតានៃ ភូមិមនោរម្យ ភូមិស្វាយ និងភូមិអន្លង់ក្រពើ [19] ។

---

*[16] ព្រះរាជក្រិត្យ លេខនស/រកត/០៧១១/៧០៧ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ ស្តីពីការស្តីពីការសម្រួលព្រំប្រទល់រដ្ឋបាល រវាងខេត្តព្រះសីហនុ និងខេត្តកោះកុងលើកទី២ ដោយកាត់យកផ្ទៃដីមួយផ្នែក ពីភូមិនេសាទ នៃឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង មកបញ្ចូលក្នុងភូមិកែវផុស នៃឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ*

*[17] អនុក្រិត្យ លេខ១៨១ អនក្រ.បក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១ ស្តីពីការបង្កើតឃុំកែវផុស នៃស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដោយកាត់យកភូមិចំនួន០៣ ពីឃុំទំនប់រលក នៃស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ គឺភូមិកែវផុស ភូមិឫទ្ធី១ និងភូមិឫទ្ធី២ និងកាត់យកដីមួយផ្នែកពីឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ*

*[18] ប្រកាស លេខ១៨៧១ ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ស្តីពីការបន្ថែមភូមិចំនួន០៣ គឺភូមិកែវផុស ភូមិឫទ្ធី១ និងភូមិឫទ្ធី២ ដែលកាត់យកពីឃុំទំនប់រលក គឺអតីតជាភូមិកែវផុស នៃឃុំទំនប់រលក ដែលបានបំបែកជា០៣ភូមិ គឺភូមិកែវផុស ភូមិឫទ្ធី១ និងភូមិឫទ្ធី២*

*[19] អនុក្រឹត្យលេខ១៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការបង្កើតឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ*

### ១៥. បង្កើតសង្កាត់កោះរ៉ុងសន្លឹម ចំណុះឱ្យ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

នៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជា ដែលមាន សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន ជាប្រមុខ បានសម្រេច ៖

-បង្កើត សង្កាត់កោះរ៉ុងសន្លឹម ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ ដោយកាត់យកភូមិចំនួន០២ នៃសង្កាត់កោះរ៉ុង គឺភូមិកោះតូច និងភូមិកោះរ៉ុងសន្លឹម [20] ។

## IV. ចំនួន និងឈ្មោះក្រុង ស្រុក ឃុំ សង្កាត់ ចំណុះខេត្ត

បច្ចុប្បន្ននេះ ខេត្តព្រះសីហនុមានប្រជាជន សរុបចំនួន ២០៨.២៣២ នាក់ មានផ្ទៃដីចំនួន ២,៦៥៨.៩០ គីឡូម៉ែត្រការ៉េ ចែកចេញជាក្រុង ១ ស្រុក ៣ គឺក្រុងព្រះសីហនុ ស្រុកព្រៃនប់ ស្រុកស្ទឹងហាវ និងស្រុកកំពង់សីលា។ ទូទាំងខេត្តព្រះសីហនុ មាន២៩ ឃុំ-សង្កាត់ និង ១១១ ភូមិ។

### ១. ក្រុងព្រះសីហនុ មាន ០៦ សង្កាត់

១. សង្កាត់លេខ០១
២. សង្កាត់លេខ០២
៣. សង្កាត់លេខ០៣
៤. សង្កាត់លេខ០៤
៥. សង្កាត់កោះរ៉ុង
៦. សង្កាត់កោះរ៉ុងសន្លឹម

### ២. ស្រុកព្រៃនប់ មាន ១៥ ឃុំ

១. ឃុំអណ្តូងថ្ម
២. ឃុំបឹងតាព្រហ្ម
៣. ឃុំបិតត្រាង
៤. ឃុំជើងគោ
៥. ឃុំអូរជ្រៅ

[20] *អនុក្រឹត្យលេខ១៦៥ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការបង្កើតសង្កាត់កោះរ៉ុងសន្លឹម ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ*

៦. ឃុំ អូរឧកញ៉ាហេង
៧. ឃុំព្រៃនប់
៨. ឃុំរាម
៩. ឃុំសាមគ្គី
១០. ឃុំសំរុង
១១. ឃុំទឹកល្អក់
១២. ឃុំទឹកថ្លា
១៣. ឃុំទួលទទឹង
១៤. ឃុំវាលរេញ
១៥. ឃុំតានៃ

**៣. ស្រុកស្ទឹងហាវ មាន ៤ ឃុំ**

១. ឃុំកំពេញ
២. ឃុំអូរត្រេះ
៣. ឃុំទំនប់រលក
៤. ឃុំកែវផុស

**៤. ស្រុកកំពង់សីលា មាន ៤ ឃុំ**

១. ឃុំចំការហ្លួង
២. ឃុំកំពង់សីលា
៣. ឃុំអូរបាក់រទេះ
៤. ឃុំស្ទឹងឆាយ

## V. សមិទ្ធិផលសំខាន់ៗរបស់ក្រុងព្រះសីហនុ

ការស្ថាបនាតំបន់ កំពង់សោម បានចាប់ផ្តើមឡើងតាំងពីឆ្នាំ១៩៥៥ មកម្លេះ ហើយមូលហេតុនៃការកសាងទីក្រុងនេះ គឺផ្តើមចេញ ពីការស្ថាបនាកំពង់ផែសមុទ្រ ។ ក្រុមអ្នកឯកទេស និងកម្មករ ដែលទៅដល់ដំបូង គឺធ្វើដំណើរតាមកាណូតពីកំពត (ផ្លូវគោកពីកំពត ទៅ រាម នៅពេលនោះប្រើប្រាស់ពុំកើតទេ

ដោយសារការកម្ទេចស្ពាន ស្ទើរតែទាំងអស់ក្នុងកំណាត់ផ្លូវនេះ ដោយសារសង្គ្រាម) រួចកាប់ឆ្ការព្រៃបោះដំរំដំបូង នៅម្តុំមាត់សមុទ្រ ត្រង់ម្តុំមន្ទីរគណៈកម្មាធិការក្រុង ។

ការងារទាំងនេះ មានការលំបាកណាស់ ព្រោះគ្មានផ្លូវគមនាគមន៍ ផ្លូវគោកតភ្ជាប់ ហើយភាពចាំបាច់ក្នុងការទំនងទំនង ជាមួយក្រុងភ្នំពេញបានឆាប់រហ័សនោះ ទាមទារត្រូវតែស្ថាបនាវាលយន្តហោះ ដែលមានបណ្តោយ៥០០ម៉ែត្រ ដែលត្រូវបានកសាងឡើងនៅខែមករា ឆ្នាំ១៩៥៦ ។ យន្តហោះតូចៗ ដែលអាចដឹកមនុស្សបាន៦នាក់ និងធ្វើដំណើរ ប្រើរយៈពេលតែមួយម៉ោងដល់ភ្នំពេញ ដែលពីមុនមក គេត្រូវការប្រើពេលយ៉ាងតិច១០ម៉ោង តាមផ្លូវគោក (ពីរម៉ោងពីភ្នំពេញ ទៅកំពត និង៨ម៉ោង ពីកំពត ទៅកំពង់សោម)។ ការប្រើប្រាស់ផ្លូវអាកាសនេះ បានជួយសម្រួលច្រើនដល់ការងារស្ថាបនា ផ្សេងៗ ទម្រាំមានផ្លូវគោក ពីភ្នំពេញ ទៅកំពង់សោម(កាត់តាមកំពត) ដែលដំណើរការ នៅពាក់កណ្តាលឆ្នាំ១៩៥៧ ។

**១. ផ្លូវជាតិលេខ៤៖** តភ្ជាប់កំពង់ផែ កំពង់សោម (កាត់តាមកំពង់ស្ពឺ) ទៅរាជធានីភ្នំពេញ ត្រូវបានគេស្គាល់ថា ជាផ្លូវហាយវេ ចាក់ក្រាលកៅស៊ូ មិត្តភាព ខ្មែរ អាមេរិក មានទទឹង ៧ម៉ែត្រ ដែលត្រូវបានស្ថាបនា នៅឆ្នាំ ១៩៥៥ និងរួចរាល់នៅឆ្នាំ១៩៦០ ក្រោមមូលនិធិរស់សហរដ្ឋអាមេរិក ។





រូបភាពលេខ១៣៖ ផ្លូវជាតិលេខ៤ ស្ថាបនានៅក្នុងឆ្នាំ១៩៥៥

**២. កំពង់ផែ៖** កំពង់ផែក្រុងព្រះសីហនុ បានចាប់ផ្តើមសាងសង់នៅក្នុងឆ្នាំ ១៩៥៦ និងដាក់សម្ពោធ ដោយរដ្ឋមន្ត្រីក្រសួងការបរទេសបារាំង លោក Louis Jacquinot នៅខែមេសា ឆ្នាំ១៩៦០។ កំពង់ផែមានជម្រៅ

ទឹក១១-១៣ ម៉ែត្រ លើកលែងតែជាចំណុច ៨-៩ ម៉ែត្រ នៅក្នុងឆានែល ដែលជិតប្លុកកោះពស់។ កំពង់ផែបានកសាងមានប្រវែង ២៨៥ ម៉ែត្រ និងអាចឱ្យចូលចត ទាំងសងខាង នូវនាវាចំនួន ៤ គ្រឿង យ៉ាងតិច (៤គ្រឿង ចំពោះនាវាដែលមានចំណុះ១០.០០០តោន) តែអាចចូលចតបាន ៦គ្រឿង ចំពោះនាវាដែលមានចំណុះប្រហែល៤.០០០តោន ។



រូបភាពលេខ១៤៖ នាវាទី១ ដែលបានចូលចត នៅផែចាស់ នាខែមេសា ឆ្នាំ១៩៦០



រូបភាពលេខ១៥៖ ទិដ្ឋភាពមើលពីលើអាកាស របស់ផែចាស់ក្រោយសាងសង់រួច នៅឆ្នាំ១៩៦០



រូបភាពលេខ១៦៖ ចំណតផែចាស់ប្រវែង២៨៥ម៉ែត្រ ជម្រៅទឹក ១១ ម៉ែត្រ អាចអោយនាវាចូលចតទាំងសងខាងបាន ០៤ គ្រឿង

តាមការគ្រោងទុក ការសាងសង់កំពង់ផែនេះ គឺគេគ្រោងសង់ សម្រាប់ការដឹកជញ្ជូនទំនិញតែ២០០ ទៅ ២៤០ ពាន់តោនប៉ុណ្ណោះ ក្នុង១ឆ្នាំ ។ ប៉ុន្តែគម្រោងនេះ ត្រូវខុសស្រឡះ ក្នុងរយៈពេលដ៏ខ្លីបំផុត គឺចាប់ពីឆ្នាំ១៩៦៤មក មានភាពកកស្ទះ ក្នុងការដឹកជញ្ជូន តាមសមុទ្របានកើតមានឡើង ដោយពេលខ្លះនាវាត្រូវរង់ចាំសំចតមានចំនួន១០ ទៅ១២គ្រឿង ។ ដើម្បីឆ្លើយតបទៅនឹងការរីកចម្រើនដ៏ឆាប់រហ័សក្នុងការដឹកជញ្ជូនតាមផ្លូវសមុទ្រនេះ គម្រោងពង្រីកកំពង់ផែ ត្រូវបានគិតគូរឡើង។

កំពង់ផែថ្មី ដែលមានទំហំធំជាងពីមុននោះ បានចាប់ផ្តើមកសាងឡើង នៅភាគខាងជើងផែចាស់ ។ ទំនប់ផែពីរបានស្ថាបនាឡើង ។ ទំនប់ផែទី១ ប្រវែង៣.០០០ម៉ែត្រ ចាក់ទៅរកកោះថ្មតូចមួយ ។ ទំនប់ទី២ មានប្រវែង៦០០ម៉ែត្រ ។ តាមគម្រោងកំពង់ផែថ្មីនេះ អាចចូលសំចតបាននាវាចំនួន២០គ្រឿង ។ ការសាងសង់កំពុងតែដំណើរការមិនទាន់ បានចប់សព្វគ្រប់ ក៏មានព្រឹត្តិការណ៍រដ្ឋប្រហារថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ធ្វើឱ្យអាក់ខានការសាងសង់នេះ រហូតមកទល់នឹងសព្វថ្ងៃនេះទៅ(តែចាប់ពីឆ្នាំ១៩៦៨មក មាននាវាខ្លះចូលសំចត បណ្តើរៗនៅកំពង់ផែថ្មីនេះហើយដែរ) ។



រូបភាពលេខ១៧៖  នាវាដឹកលោក Louis Jacquint មកសម្ពោធបើកអោយដំណើរការផែចាស់ នៅខែសីហា ឆ្នាំ១៩៦០

**៣. ផ្លូវដែក ៖** ផ្លូវដែក ពីភ្នំពេញ ទៅក្រុងកំពង់សោម កាត់តាមកំពត ចាប់ផ្ដើមកសាង នៅខែសីហា ឆ្នាំ ១៩៦០ ហើយធ្វើមកដល់កំពត នៅខែឧសភា ឆ្នាំ១៩៦៨ និងទៅដល់ក្រុងកំពង់សោម នៅចុងឆ្នាំ១៩៦៩ ។ ផ្លូវដែកមានផលប្រយោជន៍យ៉ាងខ្លាំង ចំពោះវិស័យសេដ្ឋកិច្ច ព្រោះផ្លូវដែកកាត់បន្ថយតម្លៃនៃការដឹក ជញ្ជូនទំនិញ បានច្រើនជាងការដឹកជញ្ជូនតាមផ្លូវថ្នល់។



រូបភាពលេខ១៨៖ ផ្លូវដែកពីភ្នំពេញ ទៅក្រុងព្រះសីហនុ សម្រេចបាន ១៦៦ គីឡូម៉ែត្រ



រូបភាពលេខ១៩៖ ផ្លូវដែកពីភ្នំពេញ ទៅក្រុងព្រះសីហនុ

**៤. ផ្លូវអាកាស ៖** ព្រលានយន្តហោះកងកេង ត្រូវបានកសាងនៅក្នុងឆ្នាំ១៩៦០ ដោយមានជំនួយពីសហភាពសូវៀត មានទីតាំងនៅឃុំរាម ដែលអាចចុះចត យន្តហោះធុនមធ្យម។ វាលយន្តហោះនេះប្រើប្រាស់ច្រើន នៅសម័យ លន់ នល់ ដោយសារផ្លូវជាតិលេខ៤ ត្រូវកាត់ផ្តាច់ដោយសារសង្គ្រាម ។



រូបភាពលេខ២០៖ ព្រលានយន្តហោះកងកេង ត្រូវបានកសាង នៅក្នុងឆ្នាំ១៩៦០

**៥. សណ្ឋាគារឯករាជ្យ** គឺជាសណ្ឋាគារប្រវត្តិសាស្ត្រមួយ ដែលមានទីតាំងស្ថិតនៅចម្ងាយ៥ គីឡូម៉ែត្រនៅខាងក្រៅនៃទីប្រជុំជនក្រុងព្រះសីហនុ។ ការសាងសង់សណ្ឋាគារនេះ ត្រូវបានចាប់ផ្ដើមទសវត្សឆ្នាំ ១៩៦០ និងបញ្ចប់នៅឆ្នាំ ១៩៦៤ ដែលត្រូវបាន រចនាឡើងដោយស្ថាបត្យករជនជាតិបារាំង Leroy និង Mondet ជាប្រវត្តិសាស្ត្រ ដើម្បីបង្ហាញសុទិដ្ឋិនិយមរបស់ប្រទេស នេះបន្ទាប់ពីមានឯករាជ្យភាព ពីប្រទេសបារាំង។ មហាគ្រឹះពណ៌សដ៏ធំ ដែល ទើរខាងលើសមុទ្រ ត្រូវបានគេស្គាល់ សណ្ឋាគារ "ប្រាំពីរជាន់» ហើយវាជាអគារដែលខ្ពស់ជាងគេនៅក្នុងប្រទេសនាសម័យនោះ។



រូបភាពលេខ២១៖ សណ្ឋាគារឯករាជ្យ សាងសង់ នៅទសវត្សឆ្នាំ ១៩៦០

**៦. ព្រះរាជដំណាក់** គឺជាសំណង់ប្រវត្តិសាស្ត្រមួយ ត្រូវបានសាងសង់នៅឆ្នាំ១៩៦០ នៅទីក្រុងព្រះសីហនុ ដោយស្ថាបត្យករ ជនជាតិខ្មែរ លោក វណ្ណ មូលីវណ្ណ ។



រូបភាពលេខ២២៖ ព្រះរាជដំណាក់ ត្រូវបានសាងសង់នៅឆ្នាំ១៩៦០ (រូបភាពបច្ចុប្បន្ន)

៧. ស្ថានីយអយស្ម័យយានក្រុងព្រះសីហនុ ត្រូវបានគូសប្លង់ និងស្ថាបនាដោយ លោក Georges Kondracki ជាវិស្វករជនជាតិអាល្លឺម៉ង់ នៅក្នុងទស្សវត្ស ឆ្នាំ១៩៦០ ដែលជាស្ថានីយ៍រថភ្លើង ធំបីចុង ក្រោយ ដែលបានកសាងឡើងជាផ្នែកមួយ ក្នុងការតភ្ជាប់ផ្លូវដែករវាង រាជធានីភ្នំពេញ - ព្រះសីហនុ ហើយ បានសាងសង់រវាង ឆ្នាំ១៩៦០ និងបញ្ចប់នៅឆ្នាំ១៩៦៩។




រូបភាពលេខ២៣៖ ស្ថានីយអយស្ម័យយានក្រុងព្រះសីហនុ ត្រូវបានសាងសង់ នៅក្នុងទស្សវត្ស ឆ្នាំ១៩៦០




រូបភាពលេខ២៤៖ ការទទួលស្វាគមន៍ សម្តេចនរោត្តម សីហនុ នៅស្ថានីយអយស្ម័យយានក្រុងព្រះសីហនុ



រូបភាពលេខ២៥៖ ទិដ្ឋភាពទូទៅ នាស្ថានីយអយស្ម័យយានក្រុងព្រះសីហនុ



រូបភាពលេខ២៦៖ រថភ្លើង ចូលចតនៅក្នុង ស្ថានីយអយស្ម័យយានក្រុងព្រះសីហនុ



រូបភាពលេខ២៧៖ ស្ថានីយអយស្ម័យយានក្រុងព្រះសីហនុ នាពេលបច្ចុប្បន្ន

**៨. រោងចក្រចម្រាញ់ប្រេងកាត ៖** រោងចក្រនេះ សាងសង់ពីឆ្នាំ១៩៦៦ ដល់១៩៦៨ ដោយប្រើប្រាស់ទុនចម្រុះ (៦៥ភាគរយ របស់រដ្ឋ និង៣៥ ភាគរយ របស់ក្រុមហ៊ុនអែល (Eif) បារាំង) ។ សមត្ថភាពផលិតរបស់រោងចក្រនេះ មានដល់ ៦០០.០០០ តោន តែនៅពេលនោះ គេផលិតតែ ៤០០.០០០ តោន ប៉ុណ្ណោះ ។ រីឯសេចក្តីត្រូវការពិតប្រាកដ របស់ប្រទេសនាពេលនោះ គឺមានតែ ២៥០.០០០ តោន ប៉ុណ្ណោះ ។ ដើម្បីស្រូបយកឱ្យអស់ផលិតផល ដែលរោងចក្រនេះផលិតបាន រាជរដ្ឋាភិបាលជំនាន់នោះ មានគម្រោងរកទីផ្សារអន្តរជាតិ ដើម្បីលក់ប្រេង និងការបង្កើតរោងចក្រ ជាច្រើនទៀតដូចជា៖ រោងចក្រធ្វើជី រោងចក្រប៉ិយតានជាដើម (នៅពុំទាន់បានសាងសង់នៅឡើយ) ។ ក្នុងសម័យលុន លន់ រោងចក្រនោះត្រូវខូតខាតជាដំណំដោយសារសង្គ្រាម ។



រូបភាពលេខ២៨៖ រោងចក្រប្រេងកាត ត្រូវបានកសាង នៅក្នុងឆ្នាំ១៩៦៦

**៩. រោងចក្រដំឡើងត្រាក់ទ័រ ៖** រោងចក្រនេះ ចាប់ដំណើរការនៅឆ្នាំ១៩៦៦ ដែលគ្រប់គ្រង ដោយរដ្ឋ (ក្រុមហ៊ុនជាតិដំឡើងត្រាក់ទ័រ) ។ រោងចក្រនេះដំឡើងត្រាក់ទ័ររបស់ឆេកូស្លូវ៉ាគី ។ រោងចក្រមានទំហំតូច ពុំឆ្លើយតបទៅនឹងសេចក្តីត្រូវការ របស់ប្រជាជនទូទាំងប្រទេស នាជំនាន់នោះបានទេ ។

**១០. រោងចក្រស្រាបៀរអង្គរ** ៖ ជារោងចក្ររបស់រដ្ឋ រោងចក្រនេះបានបង្កើតចេញពី ក្រុមហ៊ុនសុរាគារខ្មែរ SKD និងត្រូវបានចាប់ផ្តើមសាងសង់ ពីឆ្នាំ ១៩៦៥ ដល់ឆ្នាំ១៩៦៧[21] ហើយត្រូវបានដាក់សម្ពោធជាផ្លូវការ ថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៦៨ ក្រោមព្រះរាជអធិបតីភាពរបស់ ព្រះបាទ នរោត្តមសីហនុ។ អគាររោងចក្រនេះត្រូវបានរចនាឡើង ដោយស្ថាបត្យករល្បីល្បាញរបស់កម្ពុជា លោក វណ្ណ មូលីវណ្ណ ក្នុងអំឡុងពេល "សម័យកាលមាស" នៃស្ថាបត្យកម្មថ្មីខ្មែរ។ ក្រុងព្រះសីហនុ ត្រូវបានគេជ្រើសរើស ជាកន្លែងសម្រាប់ ការផលិតស្រាបៀរ ដោយសារគុណភាពទឹកក្នុងតំបន់នេះ ដែលសន្មត់ថាជាទឹក ដែលមានជាតិរ៉ែល្អបំផុតសម្រាប់ផលិតស្រាបៀរ។



រូបភាពលេខ២៩៖ រោងចក្រស្រាបៀរអង្គរ កសាង ពីឆ្នាំ ១៩៦៥ ដល់ឆ្នាំ១៩៦៧




រូបភាពលេខ៣០៖ សម្ពោធជាផ្លូវការ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ១៩៦៨ ក្រោមព្រះរាជអធិបតីភាពរបស់ ព្រះបាទ នរោត្តមសីហនុ

[21] *ប្រវត្តិរោងចក្រស្រាបៀរ*

**១១. រោងចក្រផលិតទឹកកក ៖** ចាប់ដំណើរការ នៅពីឆ្នាំ១៩៦៨ ។ ក្រៅពីនេះ នៅមានរោងចក្រអគ្គិសនី និង រដ្ឋាករទឹក ក៏បានបង្កើតឡើងនៅគ្រានោះផងដែរ ។

**១២. ធនាគារជាតិ** សាខាក្រុងព្រះសីហនុ និងលំនៅដ្ឋានបុគ្គលិក ត្រូវបានសាងសង់ នៅឆ្នាំ១៩៨៦ រចនាប្លង់ដោយ លោក វណ្ណមូលីវណ្ណ ។



រូបភាពលេខ៣១៖ ធនាគារជាតិ សាខាក្រុងព្រះសីហនុ និងលំនៅដ្ឋានបុគ្គលិក ត្រូវបានសាងសង់ នៅឆ្នាំ១៩៨៦

**១៣. ព្រះវិហារកាតូលិក** St Michael Church យោងតាមកំណត់ត្រាផ្លូវការ បានសាងសង់ក្នុងឆ្នាំ១៩៦០ និងសម្ពោធក្នុងឆ្នាំ១៩៦២ ហើយអគារព្រះវិហារនេះ ត្រូវបានរចនាឡើងដោយ ព្រះបិតាបូជាចារ្យកាតូលិកបារាំង លោក Ahadobery ដោយមានជំនួយពីស្ថាបត្យករកម្ពុជាដ៏ល្បីល្បាញគឺ លោក វណ្ណ មូលី វណ្ណ។



រូបភាពលេខ៣២៖ ព្រះវិហារកាតូលិក St Michael Church ត្រូវបានសាងសង់ក្នុងឆ្នាំ១៩៦០

**១៤. វត្តជោតញ្ញាណ (វត្តលើ)** ត្រូវបានកសាងឡើងនៅឆ្នាំ១៩៥៨ ដោយសម្តេចព្រះសង្ឃរាជជោតញ្ញាណោ **ជួន ណាត** និងឧបត្ថម្ភដោយ ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយ ព្រះតេជគុណ ព្រះនាម ឃឹម រាជាគណៈថ្នាក់ចត្វា និងជាអនុគណ បានកសាងកុដិ ០២ខ្នង សាលាឆាន់ ០១ខ្នង ព្រះវិហារ ១ ធ្វើអំពីបេតុង និងបានបញ្ចុះខ័ណ្ឌសីមា តាមវិន័យបញ្ញាតិព្រះពុទ្ធសាសនា នៅឆ្នាំ១៩៦៨ ក្រោមអធិបតីភាព សម្តេច ជោតញ្ញាណោ **ជួន ណាត** សម្តេចព្រះសង្ឃរាជគណៈមហានិកាយ នៃព្រះរាជាណាចក្រកម្ពុជា ។



រូបភាពលេខ៣៣៖ វត្តជោតញ្ញាណ ( វត្តលើ)

**១៥. វត្តឥន្ទញ្ញាណ (វត្តក្រោម)** ត្រូវបានកសាងឡើងនៅឆ្នាំ១៩៥៨ សម័យសង្គមរាស្ត្រនិយម ដឹកនាំ ក សាងដោយ ព្រះតេជគុណ នូ សុខ ហៅតា ព្រឹង រួមជាមួយពុទ្ធបរិស័ទ មន្ត្រីរាជការកំពង់ផែ ឧបត្ថម្ភថវិកាដោយរាជរដ្ឋាភិបាល សហការជាមួយ សម្តេចសង្ឃរាជ គណៈធម្មយុត្តិកនិកាយ ។



រូបភាពលេខ៣៤៖ វត្តឥន្ទញ្ញាណ (វត្តក្រោម)

**១៦. វិមានឯករាជ្យ** ដែលមានទីតាំងស្ថិតនៅចំនុចប្រសព្វនៃផ្លូវឯករាជ្យ (ផ្លូវធំ) និងមិត្តភាពកម្ពុជាសូវៀត តាមផ្លូវ (ផ្លូវមិត្តភាពកម្ពុជា សូវៀត) ត្រូវបានកសាងឡើង នៅក្នុងឆ្នាំ១៩៨៥ សម្រាប់ អបអរសាទរ ប្រទេសកម្ពុជាទទួលបានឯករាជ្យពីការគ្រប់គ្រងរបស់បរទេស និងជាទីបូជនីយដ្ឋានរបស់ថ្នាក់ដឹកនាំ វីរៈជនដែលស្លាប់ដោយសារសង្គ្រាម ។ ពិធីនេះត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី៧ ខែមករា និងថ្ងៃឈប់សម្រាករបស់ជាតិមួយចំនួនផ្សេងទៀត។



រូបភាពលេខ៣៥៖ វិមានឯករាជ្យ ត្រូវបានកសាងឡើងនៅក្នុងឆ្នាំ១៩៨៥

**១៧. វេទិកា ៧មករា** ត្រូវបានកសាងឡើង នៅក្នុងឆ្នាំ១៩៨៥ ដែលមានទីតាំងស្ថិតនៅឈមពីមុខ វិមានឯករាជ្យ ។



រូបភាពលេខ៣៦៖ វេទិកា ៧មករា ត្រូវបានកសាងឡើងនៅក្នុងឆ្នាំ១៩៨៥

**១៨. រូបសំណាក តោពីរ** គឺជាសំណង់ប្រវត្តិសាស្ត្រមួយ ដែលត្រូវបានសាងសង់ឡើងវិញ នៅឆ្នាំ១៩៩៦ ហើយត្រូវបានកែលម្អជាបន្តបន្ទាប់ ទៅតាមអណត្តិ នៃថ្នាក់ដឹកនាំ ក្រុង/ខេត្ត ។



រូបភាពលេខ៣៧៖ រូបសំណាក់តោពីរ ត្រូវបានកសាង នៅក្នុងឆ្នាំ១៩៩៦

**១៩. ស្ពានតេជោមរកត ឬ ស្ពានកោះពស់ឆ្លងសមុទ្រ** មានប្រវែងបណ្ដោយ ៩០០ ម៉ែត្រ កម្ពស់ពីផ្ទៃទឹក សមុទ្រ ៤០ ម៉ែត្រ ដោយក្រុមហ៊ុនរុស្ស៊ីបានចំណាយលុយ ២០ លានអឺរ៉ូ ដើម្បីសាងសង់ ភ្ជាប់ពីដែនឆ្នេរ សមុទ្រ ទៅកាន់កោះពស់។ ស្ពាននេះ ត្រូវបានដាក់សម្ពោធ នៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១១ ក្រោមអធិបតីភាពរបស់សម្ដេច ហ៊ុន សែន និងលោកជំទាវ៕



រូបភាពលេខ៣៨៖ ស្ពានតេជោមរកត ឬ ស្ពានកោះពស់ឆ្លងសមុទ្រ

## VI. ការគ្រប់គ្រងដឹកនាំខេត្ត (ពីឆ្នាំ ១៩៥៧ ដល់ឆ្នាំ ២០១៦)

- **ពីឆ្នាំ១៩៥៧ ដល់ឆ្នាំ១៩៧០**
  - លោក សារិន ឆាក
  - លោក ឌី បែលឡុង
  - លោក ហ៊ួត សំអាត
  - លោក ហ៊ីង សុខុន
  - លោក យ៉ែម មុន្នីរ័ត្ន
- **ពីឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥**
  - លោក រស់ ព្រឿង
  - លោក មូល ខ្លេង
- **ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩**
  - លោក ឱម ណាគ្រីន ហៅមិត្ត គ្រីន ជាប្រធានគណៈតំបន់
- **ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ២០០៣**
  - លោក ព្រៀម សារ៉ន ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ក្រុងកំពង់សោម

- លោក នង នាង ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ក្រុងកំពង់សោម
- លោក ជុំ ហ៊ល ប្រធានគណៈកម្មាធិការប្រជាជនបដិវត្តន៍ក្រុងកំពង់សោម
- លោក ឃឹម បូ ប្រធានគណៈកម្មាធិការប្រជាជនក្រុងព្រះសីហនុ
- ឯកឧត្តម ផ្លាំ ប៊ុនស្រ៊ន់ អភិបាលក្រុងព្រះសីហនុ
- ឯកឧត្តម អ៊ុត ដេតតូឡា អភិបាលក្រុងព្រះសីហនុ

❖ **ពីឆ្នាំ២០០៣ ដល់ឆ្នាំ២០០៨**

– **អភិបាលក្រុង៖**

+ឈ្មោះ៖ **សាយ ហាក់** ភេទ ប្រុស

+ថ្ងៃខែឆ្នាំកំណើត៖ ០៧-០៤-១៩៦១

+ប្រភេទកាំបៀវត្ស(ចុងក្រោយ)៖ ក.១.៥

+កម្រិតវប្បធម៌៖ (មិនមានទិន្នន័យ)

– **ចំនួនគណៈអភិបាលក្រុង៖** ៧ រូប ក្នុងនោះស្រី ០ រូប

– **ចំនួនមន្ត្រីចំណុះសាលាក្រុង៖** ១៩៣ រូប ក្នុងនោះស្រី ៣៣ រូប

– **សមិទ្ធិផលសំខាន់ៗ**

+អគារសាលាខេត្តថ្មី

+អគារកម្មសីលា

+ពង្រីកផ្លូវ និងសួនចែកទ្រូងវិថីឯករាជ្យ

❖ **ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៤**

– **អភិបាលខេត្ត៖**

+ឈ្មោះ៖ **ស្បោង សារ៉ាត** ភេទ ប្រុស

+ថ្ងៃខែឆ្នាំកំណើត៖ ១៧-០៤-១៩៥៤

+ប្រភេទកាំបៀវត្ស(ចុងក្រោយ)៖ ក.១.១

+កម្រិតវប្បធម៌៖ បណ្ឌិត

– **ចំនួនគណៈអភិបាលខេត្ត៖** ៧ រូប ក្នុងនោះស្រី ១ រូប

– **ចំនួនមន្ត្រីចំណុះសាលាខេត្ត៖** ២៤១ រូប ក្នុងនោះស្រី ៥០ រូប

– **សមិទ្ធិផលសំខាន់ៗ**

+ពហុកីឡាដ្ឋានខេត្ត (មានទីតាំងនៅក្បាលឆាយ)

+សាលមហោស្រព (មានទីតាំងនៅឃ្លាំងលើ)

+សាងសង់អគាររដ្ឋបាលឃុំសង្កាត់ និងមន្ទីរវិស័យ

+សួនច្បារឆ្នេរអូរឈើទាល រង្វង់មូលត្រីដូហ្វីន

+បូជនិយដ្ឋានព្រះអង្គធំ ប្រាសាទគោបុរៈទី១ (ក្លោងទ្វារប្រាសាទព្រះវិហារ) រូបសំណាកក្រឡាហោមគង់នៅសួនច្បារ ៧ មករា វិមានឯករាជ្យ

+សាងសង់វត្តអារាម និងសមិទ្ធផលវប្បធម៌ សាសនា

❖ **ពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥**

– **អភិបាលខេត្តៈ**

+ឈ្មោះៈ **ឈិត សុខុន** ភេទ ប្រុស

+ថ្ងៃខែឆ្នាំកំណើតៈ ថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៥៥

+ប្រភេទកាំបៀវត្ស(ចុងក្រោយ)ៈ ក.១.៣

+កម្រិតវប្បធម៌ៈ អនុបណ្ឌិត

– **ចំនួនគណៈអភិបាលខេត្តៈ** ៧ រូប ក្នុងនោះស្រី ១ រូប

– **ចំនួនមន្ត្រីចំណុះសាលាខេត្តៈ**

– **សមិទ្ធិផលសំខាន់ៗ**

+ជួសជុលក្រាលកៅស៊ូ ផ្លូវឯករាជ្យ លេខ១០០ (ឧតុនិយម) ត្រង់ចំនុចការិយាល័យនគរបាលចរាចរណ៍ ដល់មុខឆ្នេរថ្មី

+ជួសជុលក្រាលកៅស៊ូ ផ្លូវ២ធ្នូ ពីចំនុចសណ្ឋាគារ អេម៉ារីអូ ទៅដល់ទីតាំងការដ្ឋានសណ្ឋាគារ ហ្វូស៊ី អ៊ិនជើណាស់សូណល

+ជួសជុលពង្រីក និងក្រាលកៅស៊ូ ផ្លូវ៧មករា ពីចំនុចផ្ទះសំណាក់ថ្ងៃល្អ ដល់ផ្លូវបំបែក ៣៣៣

+ជួលជុលកែលម្អ វេទិកា ៧ មករា និងសួនច្បារ ៧មករា វិមានឯករាជ្យ

+ជួសជុលកែលម្អ រង្វង់មូលតោពីរ

+អាងស្តុកទឹកសម្ភុយ ត្រង់ចំនុចផ្លូវ៥០២

+អគាររដ្ឋបាលសាលាខេត្តព្រះសីហនុ ថ្មី

❖ **ពីថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៥ ដល់ បច្ចុប្បន្ន**

– **អភិបាលខេត្តៈ**

+ឈ្មោះៈ **យន្ត មីន** ភេទ ប្រុស

+ថ្ងៃខែឆ្នាំកំណើតៈ ថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៦២

+ប្រភេទកាំបៀវត្ស(ចុងក្រោយ)ៈ ក.១.៦

+កម្រិតវប្បធម៌ៈ បេក្ខជន បណ្ឌិត

– **ចំនួនគណៈអភិបាលខេត្តៈ** ៧ រូប ក្នុងនោះស្រី ១ រូប

– **ចំនួនមន្ត្រីចំណុះសាលាខេត្តៈ**

– **សមិទ្ធិផលសំខាន់ៗ**

+ឯកសណ្ឋានបណ្ដោះអាសន្ន សម្រាប់មន្ត្រីរាជការ សាលាខេត្តព្រះសីហនុ

+ជួសជុលក្រាលកៅស៊ូ ផ្លូវនៅក្នុងបរិវេណសាលាខេត្តព្រះសីហនុ

+ជួសជុលក្រាលកៅស៊ូ ផ្លូវ២ធ្នូ ពីចំនុច ទីតាំងការដ្ឋានសណ្ឋាគារ ស៊ី ហ៊ូ អ៊ិនធើណាស់ សូណាល ទៅដល់ រង្វង់មូលតោពីរ

+ជួសជុលពង្រីក និងក្រាលកៅស៊ូ ផ្លូវ២៨មិថុនា ពីចំនុចរង្វង់មូល អនុវិទ្យាល័យដល់រង្វង់ មូលឯករាជ្យ

+ជួលជុលកែលម្អ វេទិកា ៧ មករា និងសួនច្បារ ៧មករា វិមានឯករាជ្យ

+ជួសជុលកែលម្អ រង្វង់មូលតោពីរ

+សាងសង់រង្វង់មូលថ្មី អនុវិទ្យាល័យ

+និងសមិទ្ធិផលថ្មីៗជាច្រើនទៀត ៕

# អត្ថបទកំណាព្យ

# ស្រណោះក្លិនស្ងួន

១- ឱ! កំពង់សោម ប្រឡែងប្រលោម ព្រលឹងស្ងួនភ្ងា
ពេលពន់ព្រលប់ យប់យន់សន្ធិយា ក្រោមដួងចន្ទ្រា
រស្មីស្រទន់។

២- ទូចតូចរសាត់ រលកបោកផាត់ ភ្លឺផ្លេកគួរគន់
នឹកនួនស្ងួនភ្ងា ពុំងាតូចតន់ ចងចិត្តចង់តន់
ជំទើរមានទ្រង់។

៣- ជំទង់មានរាង កន្ទុយភ្នែកជៀង យង់យល់ឆោមយង់
ចិន្តាយោគយោល អន្ទោលអែបអង្គ ត្រចះផូរផង់
ផូរភ័ក្ត្រស្រីថ្លៃ។

៤- ដីគោកដែនកោះ អូនល្អឥតខ្ចោះ នេត្រដូចនិលថ្មៃ
កេសានួនល្អង ចារចងនិស្ស័យ អាឡោះក្លិនថ្លៃ
អាល័យក្លិនខ្លួន។

៥- ក្លែបក្លិនពុំងា ស្រណោះកាលគ្រា ឃ្លាតឆ្ងាយនឹមនួន
អូនរស់រងកម្ម ច្រើនឆ្នាំផ្ទួនៗ ព្រាត់ក្លិនព្រាត់ខ្លួន
មាសស្ងួនពៅពេញ។

៦- ព្រលឹងមាសអើយ កែស្រស់ត្រាណត្រើយ កើយទុក្ខទោម្នេញ
នឹកណាស់មាសថ្លៃ ចរណៃពៅពេញ បានជួបអូនវិញ
នែបនិត្យថ្មមថៃ។

៧- ពេលនេះនួននាង ពេញរូបពេញរាង ផូរភ័ក្ត្រដូចខែ
ជំទើរតូចតន់ បងសូមស្បថស្បែ ស្មោះអូនឥតប្រែ
សីហនុបុរី។

៨- ព្រលឹងមាសឆោម ល្អលើល្អក្រោម ប្រលោមបមបី
នឹមនួនវរលក្ខ័ណ ស្មោះស្ម័គ្រមេត្រី ក្រុងសីហនុថ្មី
អតីតមិត្តភាព។

៩- ស្ទឹងហាវព្រៃនប់ ប្រសើរលើសលប់ តំបន់ទំនាប
កំពង់សីលា សារស័ព្ទជម្រាប គ្មានវាលទំនាប
ច្រើនដំបូកភ្នំ។

១០- លក្ខណៈភូមិសាស្ត្រ ខុសប្លែកច្រើនណាស់ មានភ្នំតូចធំ
វាលរាបតិចតួច ព្រៃឈើរូតរុំ ភាគច្រើនជួរភ្នំ

ហ៊ុំព័ទ្ធក្នុងក្រៅ។

១១- គយគន់ដែនឆ្នេរ គោកកោះដីកេរ្តិ៍ ក្រសោបក្រសាវ
រាមចំការដូង អូរត្រេះអូរត្រាវ ឈ្មោះបងធ្លាប់ហៅ
ពីដើមពីដែក។

១២- កាលពីវ័យក្មេង បណ្ដើរគ្នាលេង សប្បាយអនេក
ខ្សាច់អូរឈើទាល ដីវាលទឹកភ្នែក វណ្ណៈខ័ណ្ឌចែក
ស្នេហ៍អូននិងបង។

១៣- ម្លប់ដូងសុខា យើងធ្លាប់ចរចារ សារស័ព្ទផ្ដោះផ្ដង
កំពេញបងព្រួយ ទូកមួយចម្លង ដឹកស្រស់នួនល្អង
ឆ្លងឆ្នេរទឹកសាប។

១៤- ម្លប់ឈើមាត់ឆ្នេរ បងច្រៀងបំពេរ មាសមេអូនស្ងាប
គេងកើយទ្រូងបង សារសងកំណាព្យ ឆ្នេរខ្សាច់ទឹកសាប
បងសែនអាល័យ។

១៥- ម្លប់ដើមកាបាំង បងមានសំណាង បានជួបថ្មើមថ្លៃ
រួចពីរបប មហាប្រល័យ វិលជួបចរណៃ
ផុតក្ដីចម្បែង។

១៦- ព្រលឹងមាសឆោម ក្រុងកំពង់សោម ចង់ចោមប្រឡែង
គន់ឆ្នេរសមុទ្រ ឆ្ងាយដាច់សង្វែង បុរីកន្លែង
ទេសចរណ៍កម្សាន្ត។

១៧- វាលខ្សាច់មាត់ឆ្នេរ ខ្សាច់សលើសគេ ខ្យល់ត្រជាក់ប្រាណ
កូនភ្នំខ្ពស់ទាប វាលរាបសព្វស្ថាន អបអរយើងបាន
វិលថ្កានជួបជុំ។

១៨- ដីកេរ្តិ៍ដែនកោះ សោភ័ណសម្ផស្ស សែនស្រស់មនោរម្យ
ព្រៃស្រោងវាលរាប ទំនាបបឹងធំ ខ័ណ្ឌដោយដងភ្នំ
ហ៊ុំព័ទ្ធជុំជិត។

១៩- ពេលព្រឹកព្រលឹម ទេសភាពញញឹម ប្រោះព្រំជីវិត
អាកាសបរិសុទ្ធ ល្អផុតពិតៗ នឹមនួននេបនិត្យ
គន់គាប់ចិន្ដា។

២០- អង្គុយនន្ទៀល ឆ្នេរខ្សាច់ជម្រាល ល្អល្អះអស្ចារ្យ
រំពៃគយគន់ មើលសព្វរុក្ខា បក្សីបក្សា
ហិចហើរហ្វូងហ្វាយ។

២១- អូនអើយមើលចុះ ដីកេរ្តិ៍ដែនកោះ សម្រស់ប្រិមប្រិយ
ភូមិសាស្ត្រខេត្ត សីហនុបុរី សោភ័ណទឹកដី
ស្រស់ឆើតមនោរម្យ។

២២- រសៀលជ្រាលជ្រេរ សុរិយាទាបទេរ រៀងរេគងភ្នំ
អង្គុយមាត់ឆ្នេរ រៀបរាប់ប្រាប់មុំ ឈ្មោះកោះតូចធំ
មុំស្តាប់រៀមរ៉ា។

២៣- អូនគន់កោះស្នេហ៍ កោះគីនៅក្បែរ គួរឱ្យចេតនា
កណ្តាលគង្គា ផ្ទៃទឹកខៀវថ្លា កោះថ្មីដូចផ្កា
បុប្ផាក្រពុំ

២៤- មើលកោះស្រមោច កោះដុះដាច់ដោច តាគៀវពូតផ្តុំ
រឺកោះក្របី ឫស្សីនៅជុំ ចន្ទុះជាក្រុម
សោភ័ណសោភា។

២៥- កោះត្រេះកោះពស់ កោះទាំងពីរនោះ នៅឃ្លាតពីគ្នា
កោះថាសដែកគោល ជាប់ផ្លូវនាវា កោះព្រាបកំព្រា
គ្រាំគ្រាអាត្មា។

២៦- កោះដូងរីករាយ សោភ័ណស្រស់ស្រាយ កណ្តាលជលសា
មានក្តីសង្ឃឹម អភិវឌ្ឍន៍ស្តារ ល្អល្អះអស្ចារ្យ
ចាប់ចិត្តមេត្រី។

២៧- ប្រជុំកោះរ៉ុង កោះទ្វារអន្លង់ កោះតូចភក្តី
កោះបងកោះប្អូន កោះមូលមេត្រី ឈរពាំងទឹកដី
កោះរ៉ុងសន្លឹម។

២៨- កោះតាងសាងស្នេហ៍ កោះមួយនៅក្បែរ កោះពីត្រដឹម
កោះក្តាមត្រដែត ពីលិចញញឹម កោះព្រីងទន្ទឹម
នឹងកោះត្រងោល។

២៩- កោះវាលនៅជាយ រួមមានកោះយាយ កោះតាមិនចោល
កោះចៅឃ្លាតឃ្លា រស់នៅតែលតោល បីកោះរួមចូល
ហៅពូលូវៃ។

៣០- រៀបរាប់ឈ្មោះកោះ ប្រាប់អូនស្គាល់អស់ ណាស្រស់ចរណៃ
កេរ្តិ៍កោះអូនចាំ ឱ្យជួយកែច្នៃ អភិវឌ្ឍន៍ទឹកដី
ដែនកេរ្តិ៍ខេមរា។

| | | | |
|---|---|---|---|
| ៣១- | បងចង់ឱ្យយល់ | ឱ្យស្គាល់ឫសគល់ | ខ្មែរគ្រប់អាត្មា |
| | ក្រុងព្រះសីហនុ | ដីកេរ្តិ៍ដូនតា | ចងចាំគ្រប់គ្នា |
| | | ចារជាប្រវត្តិ។ | |
| ៣២- | កុំឱ្យជួបកម្ម | កោះកេរ្តិ៍យូរឆ្នាំ | ចុះរាយហ៊ុំទ័ព្វ |
| | សោភ័ណទឹកដី | ថ្មីអភិវឌ្ឍន៍ | ការពារបន្ទាត់ |
| | | ព្រំដែនកម្ពុជា។ | |

**និពន្ធ និងចងក្រងដោយ លោក សុខ ផន អភិបាលរងខេត្តព្រះសីហនុ**

# ឯកសារយោង

- ព្រះរាជប្រកាសលេខ៥២ ចុះថ្ងៃ១៤រោជ ខែទុតិយាសាធ ឆ្នាំកុរ បញ្ចស័ក្ស ត្រូវនឹងថ្ងៃទី១១ ខែសីហា ឆ្នាំ១៩២៣
- ប្រកាសអាររេតេលោក ឡឺរេស៊ីដង្គ សុប៉េរីយ៉ើរ លេខ ១៦៤០ ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ១៩២៣ ក្នុងរជ្ជកាលព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជប្រកាសលេខ ២២ ចុះថ្ងៃទី ៩ រោជ ខែបុស្ស ឆ្នាំ ច ឆស័ក ព.ស ២៤៧៧ ត្រូវនឹងថ្ងៃទី ២៨ ខែមករា ឆ្នាំ១៩៣៥
- ប្រកាសអាររេតេ លោកឡឺរេស៊ីដង្គ សុប៉េរីយ៉ើរលេខ ៤៤០ ចុះថ្ងៃទី ១៣ ខែកុម្ភះ ឆ្នាំ១៩៣៥
- ព្រះរាជក្រមលេខ ២៣៦ន.ស ចុះថ្ងៃទី ២២ ខែវិច្ឆិកា ឆ្នាំ១៩៥៧ ស្ដីពីការ បង្កើតក្រុងកំពង់សោម ដោយហ្លួងសុរាម្រឹត ហើយរដ្ឋសភា បានអនុម័តនាថ្ងៃទី ២១ ខែសីហា ឆ្នាំ១៩៥៧
- ព្រះរាជក្រមលេខ ២៩៦-ន.ស. ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៥៩ ស្ដីពីការផ្លាស់ឈ្មោះ ក្រុងកំពង់សោម ជាក្រុងព្រះសីហនុ ដោយរដ្ឋសភា បានអនុម័តនាថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៥៩
- ច្បាប់ស្ដីពីការតំឡើងឋានៈអោយក្រុងព្រះសីហនុជារាជធានីទី២" ដែលមានចែង នៅក្នុងមាត្រាតែមួយ - ក្រុងព្រះសីហនុ ត្រូវតំឡើងឋានៈជារាជធានីទី២ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៦៤
- ច្បាប់ដែលរដ្ឋសភា បានអនុម័តលើកទី១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧០ មានសេចក្ដីដូចតទៅៈ "ច្បាប់ស្ដីពី ការប្ដូរនាម ក្រុងព្រះសីហនុ ក្រុងជូឡុង និងក្រុងខេមរភូមិន្ទ" ។ មាត្រា១ - ក្រុងព្រះសីហនុ ក្រុងជូឡុង និងក្រុងខេមរភូមិន្ទ ត្រូវមាននាមថ្មី ជាក្រុងកំពង់សោម ក្រុងគិរីរម្យ និងក្រុងកោះកុង
- អនុក្រិត្យលេខ ១៦ អ.ន.ក្រ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៨៥ ស្ដីពីការបង្កើតខ័ណ្ឌស្ទឹងហាវ
- អនុក្រិត្យលេខ ២៧ អ.ន.ក្រ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៨៧ ស្ដីពីការបង្កើតខ័ណ្ឌមិត្តភាព
- ព្រឹត្តិបត្តិ «ការយល់ដឹងអំពីប្រទេសកម្ពុជា» ចេញផ្សាយនាឆ្នាំ១៩៨៨
- ព្រះរាជក្រិត្យ នស/រកត/១២០៨/១៣៨៥ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការប្ដូរឈ្មោះក្រុងព្រះសីហនុ មកជា ខេត្តព្រះសីហនុ
- អនុក្រិត្យ លេខ១៨ អនក្រ.បក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៩ ស្ដីពីកំណត់ចំនួនសមាជិកក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ សម្រាប់អាណត្តិទី១

- អនុក្រឹត្យ លេខ២៦ អនក្រ. បកចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាល រាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- ប្រកាស លេខ១៨៧១ ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០១១ ស្តីពីការបន្ថែមភូមិចំនួន០៣ គឺភូមិកែវផុស ភូមិឬទ្ធី១ និងភូមិឬទ្ធី២ ដែលកាត់យកពីឃុំទំនប់រលក គឺអតីតជាភូមិកែវផុស នៃឃុំទំនប់រលក ដែលបានបំបែកជា០៣ភូមិ គឺភូមិកែវផុស ភូមិឬទ្ធី១ និងភូមិឬទ្ធី២
- ព្រះរាជក្រឹត្យ លេខនស/រកត/០៧១១/៧០៧ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១១ ស្តីពីការសម្រួលព្រំប្រទល់រដ្ឋបាល រវាងខេត្តព្រះសីហនុ និងខេត្តកោះកុងលើកទី២ ដោយកាត់យកផ្ទៃដីមួយផ្នែកពីភូមិនេសាទ នៃឃុំជ្រោយស្វាយ ស្រុកស្រែអំបិល ខេត្តកោះកុង មកបញ្ចូលក្នុងភូមិកែវផុស នៃឃុំទំនប់រលក ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ
- អនុក្រឹត្យ លេខ១៨១ អនក្រ.បក ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១១ ស្តីពីការបង្កើតឃុំកែវផុស នៃស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ដោយកាត់យកភូមិចំនួន០៣ ពីឃុំទំនប់រលក នៃស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ គឺភូមិកែវផុស ភូមិឬទ្ធី១ និងភូមិឬទ្ធី២ និងកាត់យកដីមួយផ្នែកពីឃុំជើងគោ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
- អនុក្រឹត្យលេខ១៦៤ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការបង្កើតឃុំតានៃ ស្រុកព្រៃនប់ ខេត្តព្រះសីហនុ
- អនុក្រឹត្យលេខ១៦៥ អនក្រ.បក ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៦ ស្តីពីការបង្កើតសង្កាត់កោះរ៉ុងសន្លឹម ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ
- សៀវភៅ ផែនការអភិវឌ្ឍន៍៥ឆ្នាំ ២០១១-២០១៥ របស់រដ្ឋបាលខេត្តព្រះសីហនុ
- តារាងឈ្មោះកោះ និងទំហំ លេខ០៣៥ អ.ដនសស/ខសន ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥
- សៀវភៅ កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០១៧-២០១៩) ខេត្តព្រះសីហនុ
- សៀវភៅ ស្រុកខ្មែរៈ ការវិវត្តចលនានយោបាយ និពន្ធដោយ សាគូ សាមុត
- ឯកសារ ប្រវត្តរោងចក្រស្រាបៀរ

## គេហទំព័រ

- https://en.wikipedia.org/wiki/Sihanoukville_Province
- http://www.akp.gov.kh/?p=79956
- https://www.canbypublications.com/sihanoukville-cambodia/sihanoukville-sights.htm
- http://traincambodia.com/timetable-prices/

# ឧបសម្ព័ន្ធ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ : ៩៤៦៩.សរាចរ

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០១២

សាលាខេត្តព្រះសីហនុ
លេខ: ......
ថ្ងៃទី .......... ម៉ោង......
បញ្ជូន..........

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ជម្រាបមក**
- **ឯកឧត្តម អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**
- **ឯកឧត្តម អភិបាល នៃគណៈអភិបាលគ្រប់ខេត្ត**

**កម្មវត្ថុ** : ស្តីពីការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ។

**យោង** : តាមការចាំបាច់ ។

តបតាមកម្មវត្ថុ និងយោងខាងលើ សូមជម្រាបឯកឧត្តមជ្រាបថា ផ្អែកតាមការវិវត្តរបស់ប្រទេសជាតិពីសម័យកាលមួយទៅសម័យកាលមួយទៀត បានធ្វើឱ្យមានការប្រែប្រួលស្ថានភាពភូមិសាស្ត្ររដ្ឋបាល ប្រជាសាស្ត្រ សេដ្ឋកិច្ច សង្គមកិច្ច និងការគ្រប់គ្រងរដ្ឋបាលនៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ ហេតុនេះ ក្រសួងមហាផ្ទៃមានគម្រោងចងក្រងនូវប្រវត្តិរបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នៅទូទាំងប្រទេស ដើម្បីរក្សាទុកជាឯកសារសម្រាប់បម្រើឱ្យការសិក្សាអំពីប្រវត្តិនៃការកកើត និងការវិវត្តនៃការគ្រប់គ្រងដឹកនាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងសម្រាប់បម្រើឱ្យការងារផ្សេងៗទៀត ។ ដើម្បីអាចសម្រេចកិច្ចការនេះបាន ក្រសួងមហាផ្ទៃ សូមស្នើឯកឧត្តមចាត់ចែងឱ្យមានការសិក្សាស្រាវជ្រាវ និងចងក្រងនូវប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់(ដូចមានមាតិកាជូនភ្ជាប់ជាមួយ) រួចហើយផ្ញើមកក្រសួងមហាផ្ទៃ ដោយភ្ជាប់មកជាមួយនូវឯកសារដែលពាក់ព័ន្ធ ប្រសិនបើមាន ។

នៅក្នុងដំណើរការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នេះ ត្រូវធានាឱ្យមានការចូលរួមផ្តល់យោបល់ឱ្យបានគ្រប់ជ្រុងជ្រោយពីអ្នកពាក់ព័ន្ធ ព្រមទាំងប្រមូលនូវឯកសារដែលជាភស្តុតាង ឬការអះអាងដែលអាចបង្ហាញអំពីស្ថានភាពពិតប្រាកដដែលបានកើតមានឡើងតាមសម័យកាលនីមួយៗនៅតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់នោះ ។

ដើម្បីឱ្យកិច្ចការនេះអាចដំណើរការបាន និងសម្រេចនូវលទ្ធផលតាមការគ្រោងទុក ក្នុងជំហានដំបូងនេះ សូមឯកឧត្តមរៀបចំចងក្រងនូវប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ណាដែលមានប្រវត្តិច្បាស់លាស់ក្នុងប្រវត្តិសាស្ត្រ និងមានសក្តានុពលបម្រើឱ្យវិស័យទេសចរណ៍ ។ បន្ទាប់មកទើបសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលនៅសល់ជាបន្តបន្ទាប់ថែមទៀត ។

អាស្រ័យហេតុនេះ សូមឯកឧត្តម [illegible] អនុវត្តតាមការគួរ ។

សូមឯកឧត្តមទទួលនូវការ [illegible]

ស ខេង

**ចម្លងជូន :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ឯកសារ កាលប្បវត្តិ

អាសយដ្ឋានក្រសួងមហាផ្ទៃ លេខ ២៧៥ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៥៩ ទូរសារ (៨៥៥) ២៣៧២៦០៥២-២៣៧២៦០៩៣ e-mial : moi@interior.gov.kh web : www.interior.gov.kh

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្តព្រះសីហនុ

លេខៈ០៤៦ ស.ណ.សាខ/១៣

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៦១ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ ។
- បានឃើញអនុក្រឹត្យលេខ ២១៦.អនក្រ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។
- យោងលិខិតលេខ ១៥៦៩.សជណ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ ស្តីពីការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រង ដឹកនាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្តព្រះសីហនុ ។

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំខេត្តព្រះសីហនុ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-ឯកឧត្តម សំ សំអាត | អភិបាលរងខេត្តព្រះសីហនុ | ប្រធាន |
| ២-លោក សុខ ផន | នាយករដ្ឋបាលសាលាខេត្ត | អនុប្រធាន |
| ៣-លោក ឯម ភាព | នាយកទីចាត់ការផែនការ និងវិនិយោគ | សមាជិកអចិន្ត្រៃយ៍ |
| ៤-លោក ផុក ស៊ីផា | ទីប្រឹក្សាក្រសួងផែនការ | សមាជិក |
| ៥-លោក សូ សុខ | ប្រធានមន្ទីរ ដ.ន.ស.ស ខេត្ត | សមាជិក |
| ៦-លោក សេង ខា | ប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ៧-លោក សេរី សម្បត្តិ | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ៨-លោក ស៊ិត ចាន់ថន | នាយកទីចាត់ការរដ្ឋបាលសាលាខេត្ត | សមាជិក |
| ១០-លោក ហួន សំរិទ្ធិ | នាយកទីចាត់ការហិរញ្ញវត្ថុ ស្តីទី | សមាជិក |
| ១១-លោក នួន ប៊ុនធុល | នាយកទីចាត់ការអន្តរវិស័យ | សមាជិក |

១២-លោក ជា បាឈុន នាយករងទីចាត់ការផែនការ និងវិនិយោគ សមាជិក

១៣-លោក អភិបាលក្រុង ស្រុក សមាជិក

១៤-លោក លោកស្រី មេឃុំ ចៅសង្កាត់ សមាជិក

**ប្រការ២.-**

ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំខេត្តព្រះសីហនុ មានតួនាទី ភារកិច្ច៖

- ធ្វើការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិនៃការកកើតខេត្តព្រះសីហនុ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំរបស់ខេត្តព្រះសីហនុ ពីសម័យកាលមួយទៅសម័យកាលមួយ ។
- ជួយផ្តល់ការណែនាំដល់ក្រុង ស្រុក ឃុំ សង្កាត់ ក្នុងការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិនៃការកកើតក្រុង ស្រុក ឃុំ សង្កាត់ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំរបស់ក្រុង ស្រុក ឃុំ សង្កាត់ ពីសម័យកាលមួយទៅសម័យកាលមួយ ។
- ធ្វើការជ្រើសរើសក្រុង ស្រុក ឃុំ សង្កាត់ណាដែលមានប្រវត្តិ និង ការវិវត្តនៃការគ្រប់គ្រងដឹកនាំច្បាស់លាស់ក្នុងប្រវត្តិសាស្ត្រ ហើយមានសក្តានុពលបម្រើឲ្យវិស័យទេសចរណ៍ ផ្ញើទៅក្រសួងមហាផ្ទៃ មួយជំហានមុន រីឯក្រុង ស្រុក ឃុំ សង្កាត់ ដែលនៅសល់ ផ្ញើទៅជាក្រោយ។
- ត្រូវរក្សាទុកដាក់ឯកសារដែលបានសិក្សាស្រាវជ្រាវ និងចងក្រងទាំងអស់ ទាំងរបស់ខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ និងឯកសារផ្សេងៗទៀត ដែលជាភស្តុតាង ឲ្យបានគង់វង្ស ។

**ប្រការ៣.-**

គណៈអភិបាលខេត្ត នាយករដ្ឋបាលសាលាខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក មេឃុំ ចៅសង្កាត់ និង ឯកឧត្តម អស់លោក លោកស្រី ដូចក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព។

**ប្រការ៤.-**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ខេត្តព្រះសីហនុ ថ្ងៃទី [illegible] ខែកុម្ភៈ ឆ្នាំ ២០១៣

អភិបាលខេត្ត

ស្បោង_សារ៉ាត

<u>ចម្លងជូន:</u>

-ក្រសួងមហាផ្ទៃ

"ដើម្បីជូនជ្រាប"

-ដូចប្រការ៣

-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**

**សាលាខេត្តព្រះសីហនុ**

លេខ: ០២៧ សសរ/១៣

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមលេខានៃក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៥៦១ ចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីការត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ ។
- បានឃើញអនុក្រឹត្យលេខ ២១៦.អនក្រ ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ២០០៩ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក។
- យោងលិខិតលេខ ១៥៦៩.សជណ ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ ស្តីពីការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រង ដឹកនាំរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- យោងសេចក្តីសម្រេចលេខ ០៩១.សសរ/១៣ ចុះថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១៣ ស្តីពីការបង្កើតក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តិនៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ ។
- យោងស្មារតីនៃកិច្ចប្រជុំក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តិនៃការគ្រប់គ្រង ដឹកនាំខេត្តព្រះសីហនុ នាថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០១៣ ។

## សម្រេច

**ប្រការ១.-**

បង្កើតក្រុមលេខានៃក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រងដឹកនាំខេត្តព្រះសីហនុ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១-លោក ឯម ភាព | នាយកទីចាត់ការផែនការ និងវិនិយោគ សាលាខេត្ត | ប្រធាន |
| ២-លោក ប្រាក់ វិសាល | នាយករងទីចាត់ការរដ្ឋបាល សាលាខេត្ត | សមាជិក |
| ៣-លោក ទ្រី ឆាយហុក | ប្រធានការិយាល័យនត្យូបនីយកម្ម នៃមន្ទីរ ជ.ន.ស.ស | សមាជិក |
| ៤-លោក ផុក ទូច | ប្រធានការិយាល័យបៀវត្ស នៃមន្ទីរផែនការ | សមាជិក |
| ៥-លោក សូ សៀង | នាយកសវនកម្មផ្ទៃក្នុងនៃមន្ត្រីកំពង់ផែស្វយ័តក្រុងព្រះសីហនុ | សមាជិក |

៦-លោក ជា បាឈុន　　នាយករងទីចាត់ការផែនការ និងវិនិយោគ　　សមាជិក

៧-លោក ឃាង ភារម្យ　　មន្ត្រីព័ត៌មានវិទ្យាខេត្ត　　សមាជិក

**ប្រការ២.-**

ក្រុមលេខាដូចក្នុងប្រការ ១ ខាងលើ មានលេខាធិការដ្ឋាននៅទីចាត់ការផែនការ និងវិនិយោគ សាលាខេត្ត ។ មានតួនាទីធ្វើសេនាធិការឲ្យក្រុមការងារសិក្សាស្រាវជ្រាវ ចងក្រងប្រវត្តិ និងការវិវត្តិនៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ ដូចខាងក្រោម ៖

- សិក្សាស្រាវជ្រាវ ចងក្រងប្រវត្តិនៃការកកើតខេត្តព្រះសីហនុ និងការវិវត្តនៃការគ្រប់គ្រង ដឹកនាំរបស់ខេត្តព្រះសីហនុ ពីសម័យកាលមួយទៅសម័យកាលមួយ ។
- ប្រមូលទិន្នន័យ/ព័ត៌មាន ទាក់ទងនឹងប្រវត្តិនៃខេត្តព្រះសីហនុឲ្យបានជាអតិបរិមា ដោយស្រាវជ្រាវឯកសារពាក់ព័ន្ធនានា និងចុះសាកសួរសាក្សីរស់ ជាចាស់ព្រឹទ្ធាចារ្យ អតីតមន្ត្រីរាជការ អតីតថ្នាក់ដឹកនាំខេត្ត និងអ្នកដែលបានដឹងពីស្ថានភាពពិត ។
- រៀបចំសេចក្តីព្រាងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រង ដឹកនាំរបស់ខេត្តព្រះសីហនុ ពីសម័យកាលមួយទៅសម័យកាលមួយ ប្រកបដោយគុណភាព និងប្រកបដោយទិន្នន័យ/ព័ត៌មានច្បាស់លាស់ គ្រប់ជ្រុងជ្រោយ ព្រមទាំងមានអំណះអំណាង ។
- សម្របសម្រួលរាល់កិច្ចប្រជុំនានារបស់ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្តនៃការគ្រប់គ្រង ដឹកនាំខេត្ត ។
- រៀបចំគម្រោងថវិកាចំណាយ សម្រាប់ប្រតិបត្តិការ និងការបោះពុម្ព ។
- បំពេញកិច្ចការផ្សេងទៀតតាមតម្រូវការរបស់ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំខេត្ត ។

**ប្រការ៣.-**

នាយករដ្ឋបាលសាលាខេត្ត ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំខេត្ត មន្ទីរ អង្គភាពពាក់ព័ន្ធ និង អស់លោក លោកស្រី ដូចក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ខេត្តព្រះសីហនុ ថ្ងៃទី[illegible]....ខែ[illegible] ឆ្នាំ ២០១៣

**អភិបាលខេត្ត**

**ស្បោង_សារ៉ាត**

<u>ចម្លងជូន:</u>
-ក្រសួងមហាផ្ទៃ
"ដើម្បីជូនជ្រាប"
-ដូចប្រការ៣ "ដើម្បីអនុវត្ត"
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រះសីហនុ**
លេខៈ១២៣/១៦ ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលប្រការ១ នៃសេចក្តីសម្រេចលេខ ០៦៧សសរ/១៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ស្តីពី ការបង្កើត ក្រុមលេខា នៃក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ

## អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨០៧ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការត្រាស់បង្គាប់តែងតាំង អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងារ របស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងលិខិតលេខ ១៥៦៩ សជណ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ ស្តីពីការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- យោងសេចក្តីសម្រេចលេខ ០៤១សសរ/១៣ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការបង្កើត ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ
- សេចក្តីសម្រេចលេខ ០៦៧សសរ/១៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ស្តីពីការបង្កើត ក្រុមលេខា នៃក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ
- យោងតាមការចាំបាច់ របស់រដ្ឋបាលខេត្តព្រះសីហនុ

# សម្រេច

**ប្រការមួយ.**_

ប្រការ១ នៃសេចក្តីសម្រេចលេខ ០៦៧សសរ/១៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ស្តីពីការបង្កើត ក្រុមលេខា នៃក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ ត្រូវបានកែសម្រួលដូចតទៅ៖

**ប្រការ១.**_ **ថ្មី**

ត្រូវបានកែសម្រួលសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. លោក ឯម ភាព | នាយករដ្ឋបាលសាលាខេត្ត | ប្រធាន |
| ២. លោក ផុក ទូច | អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត | សមាជិក |
| ៣. លោក សាន សុមែន | អនុប្រធានមន្ទីរធម្មការ និងសាសនាខេត្ត | សមាជិក |
| ៤. លោក ជា បាឈុន | នាយករងទីចាត់ការផែនការ និងវិនិយោគ | សមាជិក |
| ៥. លោក ប្រាក់ វិសាល | នាយករងទីចាត់រដ្ឋបាល | សមាជិក |
| ៦. លោក ទ្រី ឆាយហុក | ប្រធានការិយាល័យរៀបចំដែនដី និងនគរូបនីយកម្ម | សមាជិក |
| ៧. លោក សូ សៀង | នាយកផែនការ កំពង់ផែស្វយ័តព្រះសីហនុ | សមាជិក |
| ៨. លោក ហេង សាយស៊ីថន | ប្រធានការិយាល័យអប់រំក្រៅប្រព័ន្ធ | សមាជិក |
| ៩. លោក ឃាង ភារម្យ | មន្ត្រីការិយាល័យវិនិយោគ | សមាជិក |
| ១០. លោក តា ចាន់បូរិទ្ធ | មន្ត្រីទីចាត់ការផែនការ និងវិនិយោគ | សមាជិក |
| ១១. លោក សេន វ៉ន | មន្ត្រីព័ត៌មានវិទ្យាខេត្ត | សមាជិក |

**ប្រការពីរ.**_

ប្រការ១ នៃសេចក្តីសម្រេចលេខ ០៦៧សសរ/១៣ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ស្តីពីការបង្កើត ក្រុមលេខា នៃក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ ត្រូវទុកជានិរាករណ៍។

**ប្រការបី.**_

នាយករដ្ឋបាលសាលាខេត្ត ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រងដឹកនាំខេត្ត មន្ទីរអង្គភាព ពាក់ព័ន្ធ និង អស់លោក លោកស្រី ដូចក្នុងប្រការ១._ថ្មី ខាងលើ ត្រូវ អនុវត្ត សេចក្តីសម្រេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ខេត្តព្រះសីហនុ, ថ្ងៃទី...១២...ខែ...[illegible]...ឆ្នាំ២០១៦

**អភិបាលខេត្ត**

**យន្ត. មីន**

**ចម្លងជូន៖**

-ក្រសួងមហាផ្ទៃ

"ដើម្បីជូនជ្រាប"

-ដូចប្រការបី

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋបាលខេត្តព្រះសីហនុ**
លេខៈ ១២២/១៦ ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលប្រការ១ នៃសេចក្តីសម្រេចលេខ ០៤១សសរ/១៣ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការបង្កើត ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ

## អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៥/៨០៧ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការត្រាស់បង្គាប់តែងតាំង អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងលិខិតលេខ ១៥៦៩ សជណ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១២ របស់ក្រសួងមហាផ្ទៃ ស្តីពីការសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- សេចក្តីសម្រេចលេខ ០៤១សសរ/១៣ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការបង្កើត ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ
- យោងតាមការចាំបាច់ របស់រដ្ឋបាលខេត្តព្រះសីហនុ

## សម្រេច

**ប្រការមួយ.**_

ប្រការ១ នៃសេចក្ដីសម្រេចលេខ ០៤១សសរ/១៣ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការបង្កើត ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ ត្រូវបានកែសម្រួលដូចតទៅ៖

**ប្រការ១._ថ្មី**

ត្រូវបានកែសម្រួលសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្ដម យន្ត មីន | អភិបាលខេត្តព្រះសីហនុ | ប្រធាន |
| ២. លោក ឯម ភាព | នាយករដ្ឋបាលសាលាខេត្ត | អនុប្រធាន |
| ៣. លោក ផុក ស៊ីផា | ទីប្រឹក្សាក្រសួងផែនការ | សមាជិក |
| ៤. លោក នេន ម៉ាលីយ | ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | សមាជិក |
| ៥. លោក នួន ប៊ុក | ប្រធានមន្ទីរ ដ.ន.ស.ស ខេត្ត | សមាជិក |
| ៦. លោក តាំង សុចិត្រគ្រីស្នា | ប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ៧. លោក ស៊ុត ចាន់ថន | នាយករងទីចាត់ការរដ្ឋបាល | សមាជិក |
| ៨. លោក ចេន រ៉េត | នាយកទីចាត់ការផែនការ និងវិនិយោគ | សមាជិក |
| ៩. លោក ទិត ប៊ុនធឿន | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ១០. លោក ហួន សំរិទ្ធិ | នាយកទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| ១១. លោក អភិបាលក្រុង ស្រុក | | សមាជិក |
| ១២. លោក លោកស្រី មេឃុំ ចៅសង្កាត់ | | សមាជិក |

**ប្រការពីរ.**_

ប្រការ១ នៃសេចក្ដីសម្រេចលេខ ០៤១សសរ/១៣ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៣ ស្ដីពីការបង្កើត ក្រុមការងារសិក្សាស្រាវជ្រាវ និងចងក្រងប្រវត្តិ និងការវិវត្ត នៃការគ្រប់គ្រង ដឹកនាំ ខេត្តព្រះសីហនុ ត្រូវទុកជានិរាករណ៍។

**ប្រការបី.**_

នាយករដ្ឋបាលសាលាខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក មេឃុំ ចៅសង្កាត់ និង ឯកឧត្ដម អស់លោក លោកស្រី ដូចក្នុងប្រការ១._ថ្មី ខាងលើ ត្រូវអនុវត្ត សេចក្ដីសម្រេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ខេត្តព្រះសីហនុ ថ្ងៃទី...១២...ខែ...[illegible]...ឆ្នាំ២០១៦

**អភិបាលខេត្ត**

**ចម្លងជូន៖**

-ក្រសួងមហាផ្ទៃ

"ដើម្បីជូនជ្រាប"

-ដូចប្រការបី

-ឯកសារ-កាលប្បវត្តិ


Fishing Port 3km
Steung Hav Village 28km
Ferry to Koh Rong
Hun Sen Beach
eah Sihanouk
tonomous Port
Sihanouk Ville
Railway Station
Kbal Chhay 16km
Preah Sihanouk International
Airport 18km
Ream National Park 18km
Kamport 100km
Thmor Roong Resort 113km
Pich Nil Pass 123km
phnom penh 230km
Not to Scale, Indirection Only
N
W
E
S
Phe St
National Highway 4
Water Treatment Facility
Wat Leu
Angkor
Cambrew
Mithapheap Kampuchea Soviet
Borey Kamakor
Post Office
Police Station
Embassy
Street 109
Department of Tourism
Street108
FTB
Omui St
Ekareach St
Phsar Peanichakam Market
Maybank
Sopheak Mongkul St
Phsar Leu Market
Street 220
Street218
Street216
GTVC Speed Boat Head Office
Preah Sihanouk City Hall
Santapheap St
Sihanoukville High School
19 Mithona St
2 Thnou St
Serey Pheap St
Ekareach St
The Sihanoukville Children's Home and School of Hope
Preah Sihanouk Province Hospital
Golden Lion
2 Thnou
SOKHA
HOTELS & RESORTS
Sokha Beach
Aristocrat Hotel
Tourist Police Office
1 Kakada St
14 Mithona St
23 Tola St
Ocheurteal Beach
Tourist Information Centre
Otres Beach
LEGEND
Tourist Information
Hospital
BANK
Clinic
Railway
Highway
Gasoline Station
Road
Bus Station
Police Station
Hotel
Pub
Market
Post Office
Embassy
Provincial Hall
Pagoda
Public School
Restaurant


Diving
Kbal Chhay Water Fall
Ochheuteal Beach, Sihanouk Ville
Koh Rong
Victory Beach
MORAKOT Island
(Koh Poh)
MORAKOT Island
(Koh Poh) Bridge
Loumhaekay Beach
INDEPENDENCE HOTEL
RESORT & SPA
Water Supply
Authority
Independence Beach
2 Thnou
KOH RONG (KOH TOCH)
30mn
15mn
30mn
5mn
KOH PUOS
SIHANOUK VILLE
KOH RONG
SAMLOEM
KOH TAS

**រដ្ឋបាលខេត្តព្រះសីហនុ**

អាសយដ្ឋានៈ វិថី២ធ្នូ សង្កាត់៣ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

គេហទំព័រៈ www.sihanoukville.gov.kh